# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

INSTITUT BOUDDHIQUE

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ឆ្នាំទី ២៤ ខែមករា លេខ ១

ព.ស. ២៤៩៦ — គ.ស. ១៩៥២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |
| សាភណិយធម្មកថា ............ | ព្រះមហា កែ អៀន ....... | ៣ |
| ពន្លឺអាស៊ីទ្វីប (តមក) ........... | លោកភ៉យ-ប៊ុក ......... | ១១ |
| ពុទ្ធសាសនាធិប្បាយ ............ | ព្រះបាឡាត់ ទូ ឱម ....... | ១៦ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| ការប្រើអក្សរខ្មែរ ............ | នាយ គិត-ពិន ......... | ២៤ |
| រឿងគ្រូសាញ់អ្នកខ្លាំងពូកែ .......... | សាស្ត្រាចារ្យផេង-ជ្រីវ ..... | ៣១ |
| ការបណ្ដុះនិស្ស័យ (តមក) ........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... | ៣៩ |
| រឿងសាមកុក (តមក) ........... | ឧកញ៉ា ទូ-កន ......... | ៤៧ |
| រឿងអារក្សថ្លៃងរឿងម្ដេប្រាំ (តមក) .... | លោកសាង-សាវ៉ាត ....... | ៥៦ |
| **កំណត់ទិនប្បវត្តិការណ៍** | | |
| ពិធីបុណ្យជំឧឡារិកនៅវត្តដើមអំពិល ខេត្រ ប៉ោលាវ (យៀកណាម) ......... | ព្រះមហា ឈិត-កំលិន .... | ៦៩ |
| ឧត្តមគតិនៃពុទ្ធបរិស័ទវត្តលង្កា ....... | សមាគមមិត្តសាលាបាលី .... | ៧៩ |



— មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨៣រ. ០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


| PARTIE RELIGIEUSE | | Pages |
|---|---|---|
| Saraniyadhammakathâ | *Vén. Ker-Œurn* | 3 |
| La lumière de l' Asie (suite) | *M. RAY-BUC* | 11 |
| Buddhasasnadhippaya | *Vénérable Nou-Om* | 16 |

| PARTIE LITTERAIRE | | |
|---|---|---|
| Usage de la langue cambodgienne | *Monsieur KIT PINN* | 24 |
| *Crécanau, le vaillant* | *M. Phéng-Chrieu* | 31 |
| *Education morale (suite)* | *Vén. PŒUNG-PAM* | 39 |
| Histoire de SAMKOK (suite) | *Oknha NOU-KAN* | 47 |
| Les vingt-cinq récits du mauvais Génie (suite) | *M. SANG-SAVATH* | 56 |

| NOTES ET CHRONIQUES | | |
|---|---|---|
| Cérémonies religieuses de Vatt Dœum Ampil, à Baclieu (Sud-Vietnam) | *Vénérable Chhit-Komlin* | 69 |
| Idéal des bouddhistes de la pagode de Langkar. | *Association des amis de l'Ecole de PALI* | 79 |


Prix d'un abonnement annuel (12 numéros:) 183$00

# សារាណីយធម្មកថា

ព្រះមហា កែ - អឿន (វីរិយប្បញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខែត្រសៀមរាប រៀបរៀង

ឃុនសុវត្ថិផទី យូរ-អ៊ុន អ្នកពិនិត្យកែ

............

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ ខ្ញុំព្រះករុណា អាត្មាភាព នឹងសូមដកស្រង់យកសារាណីយធម៌ ដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ទ្រង់សំដែងទុកក្នុងគម្ពីរអង្គុត្តរនិកាយឆក្កនិបាត មកអធិប្បាយជាផ្លូវលោកខ្លះ ផ្លូវធម៌ខ្លះ តាមសមគួរ ដូចតទៅនេះ:

មនុស្សគ្រប់ជាតិគ្រប់ភាសា ដែលកើតមកក្នុងពិភពលោកនេះ សុទ្ធតែមានកិច្ចការ គួរប្រកបគួរប្រស្រ័យគ្នាទៅវិញទៅមក ដែលជាផ្លូវធម៌សាសនា ឬ ក៏ផ្លូវលោក ។

ក្នុងក្រុម ឬ សង្គមនីមួយៗ ត្រូវអាស្រ័យប្រស្រ័យការទាក់ទងចងបាច់គ្នាជាកំឡាំង, បើមិនមានកំឡាំងការចងបាច់គ្នាទេ, ពុំអាចនឹងប្រកបកិច្ចការប្រស្រ័យគ្នាបានឡើយ ។ កំឡាំងការចងបាច់គ្នានេះជាធម្មជាតិ

សំខាន់បំផុតក្នុងកិច្ចការគ្រប់យ៉ាង ព្រោះហេតុនោះ បុគ្គលគួររក្សាការចងជាប់គ្នាជាកម្លាំងឲ្យរឹងប៉ឹង សម្រាប់ប្រកបកិច្ចការតាមក្រុមសង្គមរបស់ខ្លួន ៗ ក្រុមសង្គមនីមួយៗ ដែលនឹងបានសេចក្ដីសុខសេចក្ដីចម្រើនអស់កាលយូរអង្វែងទៅបានមិនបែកបិត្តគំនិតគ្នា មិនប្រណែនឈ្នានិះគ្នា មិនប្រឆាំងប្រជែងប្រណាំងគ្នាជាដើម ក៏ដោយអាស្រ័យសារាណីយធម៌ ៗ

សារាណីយធម៌នោះ ប្រែថា "ធម៌ជាទីតាំងនៃសេចក្ដីរឭកដល់គ្នានឹងគ្នាទៅវិញទៅមក" មាន ៦ យ៉ាង គឺ:

១– មេត្តាកាយកម្ម – អំពើកាយប្រកបដោយមេត្តា

២– មេត្តាវចីកម្ម – អំពើវាចាប្រកបដោយមេត្តា

៣– មេត្តាមនោកម្ម – អំពើចិត្តប្រកបដោយមេត្តា

៤– លាភៈ – ការចែករំលែកលាភដល់គ្នីគ្នា

៥– សីលៈ – ការរក្សាសីលចរិយាឲ្យមានសណ្ដាប់ធ្នាប់ល្អ

៦– ទិដ្ឋិ – ការធ្វើសេចក្ដីឃើញឲ្យត្រឹមត្រូវ ៗ

សារាណីយធម៌នេះ ព្រះភគវន្តមុនីទ្រង់សំដែងថា "ម្នាលភិក្ខុទាំងឡាយ! ធម៌ទាំង ៦ យ៉ាងនេះ តែងធ្វើអ្នកប្រតិបត្តិឲ្យជាទីស្រឡាញ់ ជាទីគោរពរាប់អានរបស់អ្នកដទៃ នាំឲ្យមានសេចក្ដីសង្គ្រោះដល់គ្នានឹង

គ្នា នាំឲ្យមានសេចក្ដីមិនទាស់ទែងខ្វែងគំនិតគ្នា នាំឲ្យមានសេចក្ដីព្រមព្រៀងគ្នាជាពួកមួយ " ។

លំដាប់តពីនេះ នឹងដកស្រង់យកបទមាតិកាមួយៗ មកអធិប្បាយតាមលំដាប់រៀងទៅ ដូចតទៅនេះ :-

មេត្តាកាយកម្ម·— ភិក្ខុសាមណេរមានចិត្តមេត្តាជួយខ្វល់ខ្វាយធ្វើកិច្ចការដែលគួរធ្វើដល់គ្នានឹងគ្នា គឺ ភិក្ខុសាមណេរជាអន្តេវាសិក សទ្ធិ-វិហារិកត្រូវធ្វើកិច្ចវត្តប្រតិបត្តិដល់ឧបជ្ឈាយ៍អាចារ្យ មានការប្រគេនទឹកក្ដៅត្រជាក់នឹងឈើស្ទន់ជាដើម ។ កាលបើអន្តេវាសិកឬសទ្ធិវិហារិកមានរោគាពាធ ត្រូវតែឧបជ្ឈាយ៍អាចារ្យ ជួយព្យាបាលរក្សា មានដាក់ថ្នាំថែទាំជម្ងឺជាដើម ។ បើមិនបានធ្វើដូច្នោះទេ គ្រាន់តែមកត្រួតត្រាមើលឲ្យឃើញថាជាការអើពើដោយកាយ ។ ពុំនោះសោត ភិក្ខុសាម-ណេរទាំងឡាយឯណា កាលបើភិក្ខុសាមណេរផងគ្នាមានកិច្ចអ្វីដែលត្រូវធ្វើដោយកាយមានកាត់-ដេរចីវរជាដើម ភិក្ខុសាមណេរនោះៗ មកជាគ្នាជួយធ្វើកិច្ចការទាំងនោះ ឬកិច្ចណាមួយដែលជាកិច្ចត្រូវអាស្រ័យនឹងបុរសបុគ្គលច្រើនគ្នាទើបប្រព្រឹត្តទៅបាន ដូចជាខ្វល់ខ្វាយរកថ្នាំធ្វើថ្នាំរក្សាបព្វជិតដែលទុព្វលភាពដោយអាពាធមានគ្រុនពិសជាដើម ខាងក្រៅមានសត្វអាសិរពិសចឹកជាដើម ។

មេត្តាវចីកម្ម·— ភិក្ខុសាមណេរមានចិត្តមេត្តាជួយណែនាំប្រៀនប្រដៅធម៌វិន័យ ជួយដាស់តឿនក្រើនរលឹកចង្អុលបង្ហាញទោស គង

ផ្លូវដែលខុស ឲ្យលះបង់អំពើទុច្ចរិត ចង្អុលហេតុផលក្នុងផ្លូវដែលល្អប្រពៃ ដែលប្រកបដោយធម៌វិន័យឲ្យមានដំណើរដើរទៅក្នុងផ្លូវល្អ ។

ម្យ៉ាងទៀត ភិក្ខុសាមណេរមានមេត្តាពោលប្រស្រ័យគ្នាដោយផ្លូវបដិសណ្ឋារៈ សួរសេចក្ដីសុខទុក្ខដល់គ្នានឹងគ្នាតាមសមគួរ ឬភិក្ខុសាម-ណេរមានមេត្តាប្រាប់វិធីរៀនវិជ្ជាខាងដើមតាំងពីសរសេរ មើលទន្ទេញ បង្ហាញគន្ថធុរៈ វិបស្សនាធុរៈ ឱវាទានុសាសនី ។

មេត្តាមនោកម្ម — ភិក្ខុសាមណេរមានចិត្តមេត្តាប្រាថ្នាប៉ុនប៉ងមិនចង់ពៀរដល់គ្នានឹងគ្នា មិនបៀតបៀនដល់គ្នានឹងគ្នា ប្រាថ្នាសេចក្ដីសុខសេចក្ដីចម្រើនដល់គ្នានឹងគ្នាដោយចិត្តស្មោះត្រង់ ។

លាភៈ — ភិក្ខុសាមណេរណាបានវត្ថុណាមួយ គឺចីវរ, បិណ្ឌ-បាត, ទីដេក ទីអង្គុយឬថ្នាំកែរោគ ជារបស់ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ គួរភិក្ខុសាមណេរនោះចែករំលែកលាភនោះៗ ដល់គ្នានឹងគ្នា ឲ្យបរិភោគប្រើប្រាស់តាមដែលបានមកតិចច្រើន ។ ឧបជ្ឈាយ៍អាចារ្យក៏ដោយ កាលបើលាភសក្ការៈ កើតមានបានមកដោយធម៌ក៏ត្រូវចែករំលែកដល់សទ្ធិវិហារិក អន្តេវាសិកបរិភោគប្រើប្រាស់តាមវត្ថុដែលមានបាន ។

សីលៈ — ភិក្ខុសាមណេរត្រូវប្រព្រឹត្តខ្លួនឲ្យស្មើនឹងពួកសព្រហ្ម-ចារីទាំងឡាយដោយសីល គឺមិនត្រូវធ្វើសីលរបស់ខ្លួនឲ្យពព្រុសពពាល

សៅហ្មង ដែលជាទីរង្កៀសមិនទុកចិត្ត ដល់ពួកសព្រហ្មចារីទាំងឡាយ ត្រូវធ្វើខ្លួនឲ្យជាអ្នកបរិសុទ្ធស្អាត ប្រាសចាកសេចក្ដីវិបត្តិនៃសីល ។

ទិដ្ឋិ— ភិក្ខុសាមណេរត្រូវប្រព្រឹត្តខ្លួនឲ្យស្មើនឹងពួកសព្រហ្មចារីទាំងឡាយដោយទិដ្ឋិ គឺ សព្រហ្មចារីទាំងឡាយប្រព្រឹត្តកាយវាចាចិត្ត យ៉ាងណា ដើម្បីជាដំណើរទៅរកបញ្ញា ដែលជាគ្រឿងឃ្មាតអំពីសត្រូវ គឺកិលេសនាំជនអ្នកប្រព្រឹត្តតាមឲ្យដល់នូវសេចក្ដីអស់ទៅ នៃទុក្ខដោយប្រពៃ, ភិក្ខុសាមណេរនោះត្រូវប្រព្រឹត្ត កាយ វាចា ចិត្តឲ្យស្មើនឹងពួកសព្រហ្មចារីទាំងឡាយនោះ ។

ធម៌ទាំង ៦ យ៉ាងនេះ មានអានុភាពនាំឲ្យអ្នកកាន់អាចរលឹកដល់គ្នានឹងគ្នា ធ្វើមនុស្សឲ្យស្រឡាញ់គ្នា នាំឲ្យមានសង្គ្រោះគ្នា មិនឲ្យទាស់ទែងគ្នា ឲ្យមានសេចក្ដីព្រមព្រៀងគ្នាជាពួកមួយ ។ ព្រោះធម្មតាការរលឹកក្ដី ការស្រឡាញ់គោរពក្ដី តែងកើតមានព្រោះអាស្រ័យឧបការគុណដែលខ្លួនបានធ្វើទុកដល់គេម្យ៉ាង, ព្រោះអាស្រ័យកាយវាចាចិត្តម្យ៉ាង ។ កាលបើភិក្ខុសាមណេរ បានធ្វើសេចក្ដីខ្វល់ខ្វាយក្នុងកិច្ចធុរៈរបស់ពួកសព្រហ្មចារីដោយកាយវាចាក្ដីដោយមេត្តាចិត្ត គិតនឹងជួយមែនៗ មិនចង់បានផលប្រយោជន៍ផ្ទាល់ខ្លួន ក្នុងទីចំពោះមុខយ៉ាងណា ក្នុងទីកំបាំងមុខក៏យ៉ាងនោះដែរ, ពួកសព្រហ្មចារីបានទទួលឧបការរបស់លោកហើយ តែងមានចិត្តគិតនឹងតបស្នងសងខ្លះ ក្នុងវេលាដែលគួរ ៗ មិនត្រឹមតែ

ប៉ុណ្ណោះសោតទេ សូម្បីមិនបានជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈដោយកាយវាចា តែចិត្តប៉ុនប៉ងប្រាថ្នាសេចក្ដីសុខប្រយោជន៍ដល់គ្នានឹងគ្នាហើយ, អាការកាយវាចា ដែលសំដែងឲ្យប្រាកដចេញមកខាងក្រៅនោះ ក៏គង់មិនជាទីត្រូវដល់ភ្នែកនៃពួកសព្រហ្មចារីនោះ, បានមេត្តាចិត្តដូច្នេះហើយក៏រមែងសំដែងមេត្តាចិត្តតបស្នងវិញខ្លះមិនខាន ។

មួយទៀត ភិក្ខុសាមណេរបានលាភមកដោយធម៌ហើយមិនទុកដាក់លាក់បរិភោគប្រើប្រាស់តែម្នាក់ឯង តែងចែករំលែកដល់ពួកសព្រហ្មចារីផងគ្នា, កាលបើពួកសព្រហ្មចារីបានទទួលវត្ថុអំពីលោកណា លុះគេបានលាភមកដោយធម៌ ក៏នឹងចែករំលែកតបលោកវិញមិនខាន ។ បើទុកជាមិនធ្វើឧបការគុណក៏ដោយចុះ ប្រសិនជាភិក្ខុសាមណេរ គ្រាន់តែប្រព្រឹត្តខ្លួនឲ្យជាអ្នកមានសីលបរិសុទ្ធ ឲ្យជាអ្នកមានទិដ្ឋិ សេចក្ដីយល់ឃើញប្រពៃហើយ ពួកសព្រហ្មចារីទាំងឡាយ ក៏នឹងជ្រះថ្លាចំពោះគុណ គឺសេចក្ដីត្រេកអររបស់លោកមិនខាន ។ ភិក្ខុសាមណេរដែលប្រព្រឹត្តដូច្នេះរមែងជាទីរឭកជាទីស្រឡាញ់គោរពកោតរបស់ពួកសព្រហ្មចារីដទៃៗនាំគ្នាគិតសង្គ្រោះគ្នានឹងគ្នា ។ មនុស្សដែលវិវាទទាស់ទែងគ្នា ក៏ព្រោះមិនមានបំណងឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នាខ្លះ ព្រោះមិនមានធ្វើឧបការគុណដល់គ្នានឹងគ្នាខ្លះ ។ ចំណែកបុគ្គលដែលមានសេចក្ដីសាមគ្គីព្រមព្រៀងគ្នា ក៏ព្រោះអាស្រ័យការសង្គ្រោះគ្នាខ្លះ ព្រោះការលៃលកជូន

ស្រោលគ្នាខ្លះ ៗ កាលបើភិក្ខុសាមណេរតាំងនៅក្នុងគុណធម៌ទាំង ៦ ប្រការនេះហើយ អាចទាញចិត្តពួកសព្រហ្មចារីមិនឲ្យរីកទាស់ទែងគ្នា ធ្វើឲ្យមានសាមគ្គីជាមួយគ្នាធ្វើឲ្យជាទីស្រឡាញ់គ្នា នាំឲ្យមានសេចក្តីសង្គ្រោះគ្នា មិនឲ្យទាស់ទែងខ្វែងគំនិតគ្នា ឲ្យមានសេចក្តីព្រមព្រៀងគ្នា ៗ

ធម្មតាបុគ្គលដែលគ្មានមិត្ត កាលបើកិច្ចធុរៈកើតឡើងម្តង ៗ ត្រូវតែខ្វល់ខ្វាយខ្នះខ្នែងកខ្វេសខ្វាសដោយកម្លាំងខ្លួនម្នាក់ឯង មិនមានបុគ្គលដទៃជួយផង ៗ រូបកាយមានដៃជើងសម្រាប់ជួយ បើខ្វះដៃឬជើងរមែងមានសេចក្តីលំបាក: ដើមឈើមានឫសនឹងមែកសម្រាប់ជួយឲ្យរស់នៅបាន បើរុក្ខាវយវៈទាំងនោះគ្មានទេ ដើមឈើនោះក៏រស់នៅមិនបាន, ត្រូវខ្យល់បក់មករលំបានដោយងាយ ៗ ធម្មតាមនុស្សទាំងពួងបើរួបរួមគ្នាច្រើន ក៏រមែងមានកម្លាំងច្រើន ៗ អម្បោះមួយសរសៃមិនស៊ូតដាច់ប៉ុន្មានទេ ទាញតែមួយប្រិបក៏ដាច់ បើវេញចូលជាធ្លុងមួយ ទើបទាញមិនដាច់ បើទុកជាគោទាញក៏មិនដាច់ ៗ ស្រមោចមួយនាំទឹងទៅជាអ្វី? មនុស្សយើងក៏ដូចគ្នាដែរ ចំពោះខ្លួនមួយទឹងតស៊ូអ្នកណាក៏មិនឈ្នះ ធ្វើអ្វីក៏មិនបានច្រើនដែរ, លុះតែជួយគ្នាទើបបានកម្លាំងច្រើនឡើង, ដោយហោចទៅ សូម្បីនៅក្នុងទីណា ហើយក្រឡេកមើលជុំវិញមិនស្គាល់អ្នកណាម្នាក់សោះ ក៏រមែងមិនបានសុខ ៗ ព្រោះហេតុដូច្នេះសេចក្តីមេត្រីស្និទ្ធស្នាលគ្នាល្អ ទើបជាផលដែលបុគ្គលត្រូវស្វែងរកយ៉ាងក្រៃលែង

សមដូចពុទ្ធភាសិតថា វិស្សាសា បរមា ញាតី · សេចក្ដីស្និទ្ធស្នាល មេត្រីរាប់អានគ្នា ជាញាតិយ៉ាងក្រៃលែង ។ ឯសេចក្ដីមេត្រីនោះ តែងកើតឡើងដោយសារាណិយធម៌ទាំង៦ យ៉ាង ដូចសំដែងមកនេះ ។ ធម្មតាបុគ្គលដែលជាទីស្រឡាញ់គោរពរាប់អានរបស់ប្រជុំជន ក៏ព្រោះអាស្រ័យឧបការគុណដែលខ្លួនបានធ្វើទុកដល់គេ ។ បើបុគ្គលបានធ្វើសេចក្ដីខ្វះខ្វែងខ្វល់ខ្វាយក្នុងកិច្ចធុរៈរបស់គ្នានឹងគ្នា ដោយកាយវាចាក្ដី ដោយមេត្តាចិត្តគិតនឹងជួយពិតៗក្ដី មិនមានបំណងផលប្រយោជន៍ ក្នុងទីចំពោះមុខយ៉ាងណា ក្នុងទីកំបាំងមុខក៏យ៉ាងនោះដែរ អ្នកដែលបានទទួលឧបការដូច្នោះ ក៏នឹងមានចិត្តសោមនស្សស្មោះសរចំពោះឧបការគុណ គិតនឹងតបស្នងឧបការខ្វះក្នុងវេលាដែលគួរ ។ អ្នកដែលទទួលមេត្រីចិត្តដូច្នេះ ខាងក្រោយក៏នឹងសំដែងមេត្រីចិត្តតបវិញ ។

ម្យ៉ាងទៀត កាលបើបានទ្រព្យសម្បត្តិដោយផ្លូវល្អ ហើយមិនលាក់លៀមទុកបរិភោគប្រើប្រាស់តែម្នាក់ឯង អាចចែករំលែកដល់បុគ្គលដែលគួរឲ្យតាមមានតាមបាន, អ្នកដែលទទួលសេចក្ដីសង្គ្រោះដូច្នោះ ក៏នឹងមានចិត្តសោមនស្សស្រឡាញ់ បើបានទ្រព្យអ្វីៗ ក៏នឹងរំលែកចែកមកវិញ ។ សមដូចភាសិតថា បូជកោ លភតេ បូជំ "អ្នកបូជាគេ រមែងបានគេបូជាវិញ" វន្ទកោ បដិវន្ទនំ "អ្នកសំពះគេ រមែងបានគេសំពះវិញ" ភាសិតខ្មែរថា "បោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់" ។

(មានត)

# ពន្លឺអាស៊ី
## វគ្គទី ៣

**La Lumière de l'Asie**

*លោក ស៊ែរ-អេតវិន អារណូលត៍ តែង*

## លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

តែកាលណាព្រះមហាក្សត្រិយ៍បានជ្រាបថា៖ "ព្រះសិទ្ធត្ថស្តេចយាងមកដល់ ដាក់ព្រះកេសា, ស្លៀកពាក់សំពត់ពណ៌ប្រផេះ របៀបជាអ្នកសូមហើយកាន់អម្បែងសូមទានភោជនាហារ ដែលសេសសល់អំពីអ្នកមានវណ្ណៈទាប" ដូច្នេះហើយទ្រង់កើតទុក្ខលំបាកក្នុងព្រះរាជហឫទ័យពន់ពេក ហើយទ្រង់ព្រះក្រោធជាខ្លាំង ។ ព្រះរាជាទ្រង់ព្រះនុជ្ជហា (ស្មោះ) លើផែនដីដោយខ្ចីមអើមណាស់, ទ្រង់បោចព្រះហនុកមស្សុ (ពុកចង្កាពុកមាត់) ដែលមានពណ៌សដូចប្រាក់ ហើយទ្រង់ចេញពីព្រះបរមរាជវាំងដោយឆាប់រហ័ស ។ ពួកអាមាត្យសេនាញ័ររន្ធត់ជាខ្លាំងក្នុងពេលដែលទ្រង់កំពុងស្តេចទៅ តាមវិថីនៃព្រះរាជធានី ។ ព្រះរាជាទ្រង់គង់ព្រះទីនាំងអស្សតេរ ទ្រង់ញាក់ព្រះក្ងមោ (ចំពៀម) ដោយទ្រង់ព្រះក្រោធជាខ្លាំង, ហើយគោះដែកឈ្នាន់ទៅលើពោះអស្សតេរ បំផាយយ៉ាងលឿនទៅតាមមហាវិថីនិងវិថីក្នុងព្រះរាជធានី ដែលពោរពេញទៅ

ដោយបណ្ដារាស្ត្រណែនណាន់តាន់តាប់មានចិត្តងឿងឆ្ងល់នឹងព្រះអាការៈនៃព្រះវរបិតា ហើយពោលស្ទើរមិនទាន់ថា៖ "សូមថ្វាយបង្គំព្រះករុណា" មុនអស្សតររត់លឿនទៅមុខ ៗ ក្នុងពេលនោះ, នៅប្របជញ្ជាំងវត្តដែលគេក្រឡេកទៅឃើញក្លោងទ្វារព្រះបរមរាជវាំងខាងត្បូង, ព្រះមហាក្សត្រិយ៍ទ្រង់បានទតទៅឃើញមហាជនជាច្រើន គឹកកងរំពងឈរត្រៀបត្រាបាំងផ្លូវជិត, ហើយមានបណ្ដារាស្ត្រប្រមូលចូលមករួបរួមជាថ្មី ឈរបន្តគ្នាណែនណាន់តាន់តាប់ដើរតាមក្រោយនៃព្រះសិទ្ធត្ថ ដែលមានព្រះនេត្រាក្លីស្រឡះហោលទៅចំព្រះវរបិតា ៗ. ដល់ព្រះសម្មាសម្ពុទ្ធទ្រង់ទតដោយទឹកព្រះទ័យដ៏ទន់ភ្លន់ ព្រមទាំងគារវភាពទៅកាន់ព្រះវរបិតាដែលទ្រង់កំពុងក្រោធជាខ្លាំង, ព្រះទ័យព្រះវរបិតាក៏អន់ថយចុះ ហើយទ្រង់ក៏លុតព្រះជន្នុកា (ជង្គង់) ចំពោះព្រះដ៏មានព្រះភាគ ព្រោះព្រះវរបិតា ទ្រង់មានព្រះទ័យស្មោះចំពោះព្រះរាជឱរសពន់ពេក ទ្រង់មានព្រះរាជបំណងចង់យល់ច្បាស់លាស់ នូវព្រះកិត្តិគុណជាអស្ចារ្យនៃព្រះរាជឱរស ដែលមានឆព្វណ្ណរង្សីផ្សាយចេញពីព្រះនលាដ៍ ហើយនឹងអាកប្បកិរិយាគួរឲ្យជ្រះថ្លាពន់ពេក ដែលនាំឲ្យមនុស្សជាច្រើនដើរតាមក្រោយព្រះរាជឱរស ដោយសេចក្ដីស្ងប់ស្ងៀម ៗ តែព្រះវរបិតាទ្រង់មានព្រះបន្ទូលទៅព្រះរាជឱរសថា "ហេតុម្ដេចក៏ព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់ប្រសើរផុត ត្រឡប់មកកាន់ព្រះរាជធានី បែរជាទ្រង់ព្រះពស្ត្រកណ្ដាប

វែហក ? ដាក់ព្រះកេសា ? ទ្រង់ព្រះស្រុតណាំបាទសង្រែក ហើយទ្រង់ទទួលទានក្រយាហាររបស់បុគ្គលដែលមានវណ្ណៈទាប ? ព្រះអង្គម្ចាស់ក្រែងទ្រង់មានជីវភាព ដូចជាព្រះអាទិទេពឬ ? ព្រះរាជបុត្រ ! ទ្រង់ជាព្រះរាជទាយាទ សោយរាជ្យនៅព្រះរាជអាណាចក្រដ៏ធំទូលាយអស្ចារ្យ ជាស្តេចចក្រពត្រាធិរាជ មានឫទ្ធានុភាព គ្រាន់តែទ្រង់ទះព្រះហស្តតល (បាតដៃ) ប៉ុណ្ណោះ ក៏ពួកអាមាត្យអាចយកព្រះក្រយាហារមកថ្វាយទ្រង់មួយរំពេចបាន ។ ព្រះអង្គម្ចាស់គួរតែទ្រង់ត្រឡប់វិលមកព្រះរាជនិវេសនដ្ឋានវិញ តាមព្រះរាជកិត្តិយសមានពួកទាហានកាន់លំពែង ព្រមទាំងមនុស្ស អស្សតរហែហមជាបរិវារទើបគួរ ។ ព្រះអង្គម្ចាស់ទ្រង់ទតមកឃើញទាហានបិតានៅឈរចាំយាមគ្រប់ផ្លូវ ហើយប្រជារាស្ត្រនៅក្នុងព្រះរាជធានី បានចេញទៅរង់ចាំធ្វើបដិសណ្ឋារៈទ្រង់ នៅខាងមុខក្លោងទ្វារធំ, តើក្នុងប៉ុន្មានឆ្នាំមុននេះទ្រង់គង់នៅទីណា ? ឯបិតាសោយរាជសម្បត្តិជាទុក្ខលំបាកពន់ពេក ហើយព្រះអគ្គជាយារបស់ទ្រង់រស់នៅដូចជាស្ត្រីមេម៉ាយ លះបង់អាមិសក្នុងលោកទាំងអស់, លែងសវនានូវចម្រៀងភ្លេងតូរ្យតន្ត្រី ហើយបោះបង់លែងគ្រងព្រះភូសាសម្រាប់បុណ្យសប្បាយសោះឡើយ ទាល់មកដល់សព្វថ្ងៃនេះ ។ ពេលនេះ, ព្រះនាងទ្រង់ព្រះភូសាប៉ាក់ដោយឌិនមាស រង់ចាំទទួលព្រះស្វាមី ដែលគ្រងសំពត់កណ្តាបលឿង, ហើយថែមទាំងកាន់អម្បែងដើរសូមទានគេទៀត ព្រះអង្គម្ចាស់ហេតុម្តេចក៏ទ្រង់ធ្វើយ៉ាងដូចនេះ ?" ។

ព្រះសម្មាសម្ពុទ្ធទ្រង់តបទៅព្រះវរបិតាថា: "នេះជាប្រវេណីរបស់តថាគតពីបុរាណមក" ។

ព្រះវរបិតាទ្រង់តបវិញថា: "ប្រវេណីទ្រង់ គឺព្រះមហាក្សត្រិយ៍សោយរាជសម្បត្តិមួយវង្សសន្តតិវង្សមកហើយ តាំងពីព្រះបាទមហាសម្មត: (មហាសម្មតិរាជ) តែព្រះមហាក្សត្រិយ៍ទាំងអស់នោះ ទ្រង់មិនដែលប្រព្រឹត្តបែបនេះឡើយ" ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះបន្ទូលតបវិញថា: "តថាគតមិនបាននិយាយអំពីសន្តតិវង្សតាមភាពសាមញ្ញនេះទេ និយាយអំពីព្រះពុទ្ធវង្សតាំងអំពីអតីតកាលទីងអនាគតកាល ។ ក្នុងចំណោមព្រះពុទ្ធទាំងអស់ តថាគតជាព្រះពុទ្ធមួយព្រះអង្គ ទើបនឹងត្រាស់ដឹងក្នុងពេលនេះ ហើយប្រវេណីព្រះពុទ្ធធ្លាប់ប្រព្រឹត្តពីបុរាណយ៉ាងណា, តថាគតក៏ត្រូវធ្វើតាមយ៉ាងនោះ, ហើយព្រឹត្តិការណ៍ដែលកើតក្នុងពេលនេះ គឺកើតតាំងពីពេលមុនដូចគ្នា ។ រឿងរ៉ាវពីអតីតកាល មានព្រះមហាក្សត្រិយ៍មួយព្រះអង្គ ទ្រង់យាងមកដល់ខាងមុខព្រះរាជដានី ដើម្បីនឹងរង់ចាំទទួលព្រះរាជឫសេ ដែលស្រង់ស្បង់ដូចតាបស ហើយជាពោធិសត្វដែលមាននិស្ស័យត្រាស់ជាព្រះពុទ្ធក្នុងកប្បនេះ ប្រកបដោយព្រហ្មវិហារដ៏ប្រសើរ ហើយមានព្រះទ័យរឹងប៉ឹង ព្រមទាំងពលភាព, ក្រាបសំពះព្រះមហាក្សត្រិយ៍ ដូចតថាគតធ្វើក្នុងពេលនោះ (ប្រហែលគ្រាន់តែធ្វើគារវភាព) ហើយក៏បាន

បូជាដោយកតញ្ញូកតវេទី ចំពោះបុគ្គលដែលមានគុណូបការៈ សម្បើមអស្ចារ្យនូវកំណាប់ទ្រព្យ ដ៏វិសេសវិសាលដែលទ្រង់បានរកឃើញ កំណាប់ទ្រព្យនេះហើយដែលគថាគតយកមកថ្វាយក្នុងពេលនេះ" ។

ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះកន្លាហើយទូលសួរទៅព្រះសម្មាសម្ពុទ្ធថាៈ "តើកំណាប់ទ្រព្យនោះនៅឯណា?" ។ ព្រះបរមគ្រូជាម្ចាស់ទ្រង់បានកាន់ព្រះហស្ដព្រះវរបិតា ហើយទ្រង់ត្រាច់តាមវិថីជាមួយនឹងប្រជាកស្ដ្រ ដែលមានអាការៈ សំដែងសេចក្ដីគោរពជាយ៉ាងក្រៃលែង, ហើយទ្រង់តបទៅព្រះវរបិតាវិញ អំពីធម៌ដែលនាំមនុស្សទៅកាន់សេចក្ដីសុខ សេចក្ដីបរិសុទ្ធ គឺធម៌ចតុរារិយសច្ចដែលមានប្រាជ្ញាជាមូលធម៌ប្រៀបដូចជាមាត់សមុទ្រ ស្ថិតនៅជុំវិញសមុទ្រដូចនោះ, ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាអំពីបទបញ្ញត្តិ ៨ យ៉ាង ដែលព្រះមហាក្សត្រិយ៍ឬពួកទាសកម្មករ មានប្រាជ្ញាចង់ត្រាច់ទៅតាមអរិយមគ្គ ដែលមានសភាពជា ៤ ថ្នាក់ ហើយនឹងសិក្ខាបទ៨ប្រការ ដែលអ្នករស់នៅប្រកបដោយពលភាព ឬខ្សោយលំបាក, អ្នកវិញ្ញូជន ឬល្ងង់, បុរស ឬស្ត្រី, ក្មេង ឬចាស់ ត្រូវតែថ្ងៃណាមួយមានបំណងចាកចេញពីកងនៃជីវភាព ទៅកាន់ព្រះនិព្វានជាស្ថានបរមសុខ ។

(មានត)

## ពុទ្ធសាសនាធិប្បាយ

# ព្រះបាឡាត់ នូ-ឱម វត្តព្រះពុទ្ធមានបុណ្យ ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ រោចខែផល្គុន

ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ (៨-៤-៤៨)

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះដ៏មានបុណ្យ អរហន្តសម្មាសម្ពុទ្ធអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

វេលានេះ អាត្មាភាពនឹងសូមលើកយកផលប្រយោជន៍នៃពុទ្ធសាសនា មកអធិប្បាយ ដោយសង្ខេប ដើម្បីឲ្យពួកខេមរបុត្រទាំងអស់ក្នុងកម្ពុជរដ្ឋ គិតជញ្ជឹងរំពឹងពិចារណា ក្នុងចិត្តគ្រប់ៗ គ្នាឲ្យឃើញជាក់ច្បាស់ថា ជាសាសនាមានដំឡៃថ្លៃថ្នូរ ក្នុងផ្លូវលោកផង ផ្លូវធម៌ផង ជាសាសនាប្រដៅមនុស្សឲ្យភ្ញាក់កំណើតឆើតទៅមុខផង ជាសាសនាប្រដៅមនុស្សឲ្យចងសាមគ្គីធម៌គ្នា ជាលទ្ធិរួមសម្លាប់កាប់ឧបសគ្គណាមួយ ដែលជាគ្រឿងរាំងក្នុងលោកផង ជាសាសនាអាចសង្កត់សង្កិនទូវពួកជនដែលពួនតែខ្លួន យកសុខផ្ទាល់ខ្លួនតែម្នាក់ឯងផង ដូចសេចក្ដីដែលនឹងថ្លែងតទៅនេះ ។

ក៏ពាក្យថាសាសនាៗ នេះ គឺជាបង្គោលឬជាទីពឹងផ្អែកយ៉ាងសំខាន់ថ្លៃថ្លារបស់ពួកជនក្នុងសាកលលោក តាំងពីបុរាណសម័យព្រេងនាយ

មក ។ តួយ៉ាងដូចជនជាតិខេមរៈយើងនេះសឹងជាអ្នកសំដែងសេចក្ដីគោរពពាប់អាន ដោយស្មោះត្រង់អស់ពីចិត្តចំពោះពុទ្ធសាសនា ខ្វល់ខ្វាយរក្សាគ្រប់ៗគ្នា អស់ចំនួនជាងពីរពាន់ឆ្នាំមកហើយ ។

ពាក្យថា សាសនា នេះ ប្រែថា "វាចាជាគ្រឿងប្រៀនប្រដៅ" ឬថា "ពាក្យបណ្ដាំ" ពុទ្ធ: នេះជាឈ្មោះរបស់មហាបុរស ដែលបានប្រកាសសាសនាទុក ។

រួមពាក្យ ពុទ្ធ: នឹង សាសនា ទាំងពីរនេះភ្ជាប់គ្នាជា ពុទ្ធ-សាសនា ៗ នេះសំគាល់សេចក្ដីថាវាចាជាគ្រឿងប្រៀនប្រដៅរបស់ព្រះសក្យមុនីគោតមសម្ពុទ្ធដែលជាបុគ្គលដើមកំណើតព្រះ ដែលពុទ្ធបរិស័ទទាំងឡាយភ្ជាប់គោរពពាប់អានរៀងៗមក ជាសាសនាយ៉ាងចំណានល្អបំណាប់ពន់ពេក ទុកឲ្យសត្វទាំងឡាយក្នុងសកលលោក ប្រតិបត្តិតាមដោយមធ្យ័តដើម្បីនឹងកំចាត់សេចក្ដីទុក្ខសោកគ្រប់យ៉ាង ហើយឲ្យបានសេចក្ដីសុខក្សេមក្សាន្តយ៉ាងអស្ចារ្យ ។

ព្រោះហេតុដូច្នោះ ព្រះពុទ្ធបាននាមប្រាកដថាជាម្ចាស់នៃសាសនា គឺព្រះធម្មសាមី ព្រោះទ្រង់ព្រះមេត្តានឹងប្រោសប្រាណ ព្រះរាជទានទូវព្រះធម៌ដែលទុកជាច្បាប់ដំរើងប្ថាន ឲ្យសត្វកាន់តាមលំអានឋានន្តរៈនឹងដំរៀវថ្ងៃរបស់ខ្លួន ។

នរជនណាដែលមានសន្តានចិត្តជោគជាប់នៅក្នុងលោកនេះ ខ្លាំងក្រាស់ក្រែនហួសប្រមាណពេក គឺថាមានចិត្តដែលជាប់ជំពាក់ជោកមិនគិតខ្លួន គេអង្រែងមិនញញើតមិនរអើ ព្រោះអគ្គិកំទៅដង់ប្រោសព្រះកដទានធម៌យ៉ាងដាន់ពាប ឲ្យត្រូវតាមអធ្យាស្រ័យតាមសភាព តាមបែបនៃនរជននោះ ឲ្យយ៉ាងដូរ។ ល្អមៗ ពីពេះស្តាប់ សង្គ្រោះតាមភាពនៃមនុស្សដែលមានឥន្ទ្រិយអន់ ទ្រង់ប្រដៅឲ្យប្រកបការងារក្នុងបច្ចុប្បន្ន ដែលជាប្រយោជន៍ឃើញជាក់ទាន់ហន់នឹងភ្នែក ឲ្យបានស្រាកស្រាន្តពាកសេចក្តីទុក្ខបានសុខគ្រប់ៗប្រាណ ។

ប៉ុន្តែក្នុងពេលនេះ ទីងសូមលើកយកផលប្រយោជន៍យ៉ាងសំខាន់របស់មនុស្សក្នុងបច្ចុប្បន្នមកបង្អុលបង្ហាញ ឲ្យឃើញជាក់ច្បាស់គ្រប់ៗគ្នាយ៉ាងនេះថា:

១ — កើតមកជាមនុស្សត្រូវតែឲ្យមានសេចក្តីព្យាយាមប្រឹងប្រែងជ្រៀតជ្រៀតប្រដែងធ្វើការងារចិញ្ចឹមជីវិត កុំខ្ជិលច្រអូស កុំថយក្រោយឲ្យសោះ ត្រូវតែរុករកកុំរួញរា ។

២ — ត្រូវឲ្យមានសីលធម៌ក្នុងចិត្ត និង ត្រូវឲ្យស្រឡាញ់សេចក្តីសុខរៀបរយ កុំនិយាយពាក្យនាំឲ្យបែកសាមគ្គីធម៌ ។

៣ — ត្រូវឲ្យប្រតិបត្តិតាមច្បាប់សម្រាប់ស្រុកដោយម៉ត់ចត់ ជួយគយគន់រកមើលហើយបង្ហាញ កុំទុកឲ្យណាក់មនុស្សធ្វើខុសច្បាប់ផ្សេងៗនឹង

អ្នកមានចិត្តក្បត់ចំពោះម្ចាស់ផែនដី ដែលព្រះអង្គទ្រង់ទសពិធរាជធម៌ មានទឹកព្រះរាជហឫទ័យ ពោលគឺមេត្តាផ្សាយទៅលើនាហ្មឺនសព្វមុខ-មន្ត្រីនិងអាណាប្រជានុរាស្ត្រទាំងអស់ ។

៤ – ត្រូវស្រឡាញ់ប្រទេសជាតិ សាសនា មហាក្សត្រ ហើយខំនាំគ្នារក្សាស្រុកទេសរបស់ខ្លួន ត្រូវពួតដៃគ្នាការពារអន្តរាយគ្រប់ផ្លូវ ដើម្បីធ្វើប្រទេសជាតិយើងឲ្យចំរើនរុងរឿងទាន់នានាជាតិជុំខ្លួន ។

៥ – ត្រូវឲ្យមានសេចក្តីចេះដឹងចូលចិត្តក្នុងផ្លូវរដ្ឋនិយម ហើយខំនាំគ្នាប្រតិបត្តិឲ្យបានផលប្រយោជន៍ទាន់ភ្នែក កុំឲ្យជាតិដទៃហៅទៅប្រើដូចជាគោក្របី ។

៦ – ត្រូវឲ្យចេះប្រើសិទ្ធិអំណាចស្មើភាគគ្នា និងសេចក្តីគោរពតាមសមគួរដល់ច្បាប់ និងប្រវេណីនិយម ដែលឥតទាស់ខុសនឹងច្បាប់ ។

៧ – ត្រូវឲ្យយកចិត្តទុកដាក់ ក្នុងការធ្វើស្រែចំការច្បារដំណាំ ដ្បិតការធ្វើរបរនេះ មានប្រយោជន៍ដល់ប្រទេសជាតិនិងរាជការរដ្ឋបាលជាសំខាន់បំផុត ។

៨ – មាតាបិតាត្រូវដឹកនាំបង្ខំបុត្របុសស្រី ឲ្យខិតខំរៀនសូត្រចំណេះវិជ្ជាមានលេខនិងអក្សរជាដើម ដែលជាផ្លូវលោកក្តី ផ្លូវធម៌ក្តី កុំបណ្តែតបណ្តោយឲ្យកូននៅល្ងង់ខ្លៅ ព្រោះការដែលសិក្សាវិជ្ជា ក៏ដើម្បី

ឲ្យកើតបញ្ញា គិតឃើញដោយខ្លួនឯងក្នុងមួយថ្ងៃៗ មិនមែនសម្រាប់តែយកកាកគំនិតរបស់គេ មកប្រើគ្រប់បែបយ៉ាងនោះទេ ។

៩ – សូមឲ្យពួកខេមរបុត្រគ្រប់ស្រុកគ្រប់ភូមិ-ធំតូច ខំបោសសំអាតទីភូមិស្ថានផ្ទះសម្បែង កន្លែងដេក-អង្គុយ គ្រឿងបរិភោគគ្រឿងស្លៀកពាក់ គ្រឿងប្រើប្រាស់គ្រប់មុខជាដើម នឹងសំអាតកូនចៅធំ-តូចកុំឲ្យមានកើតកមរមាស់ តាមវិធីអនាម័យផ្សេងៗ ។

អាត្មាភាពដែលសំដែងពន្យល់អស់លោក-អ្នកយ៉ាងនេះ មិនមែនជាការទាស់ខុសនឹងព្រះពុទ្ធដីកាទេ ព្រោះព្រះអង្គទ្រង់សំដែងពន្យល់អំពីប្រយោជន៍បច្ចុប្បន្ន ល្អិតជាងនេះទៅទៀតរហូតដល់ទ្រង់ហាមមិនឲ្យចាយវាយទ្រព្យសម្បត្តិខ្ជះខ្ជាយហួសប្រមាណពេក ។

នែពួកខេមរបុត្រ! បើអ្នកពិតជាខេមរសុទ្ធមែន ចូរអ្នកប្រឹងប្រយ័ត្នគោរពប្រតិបត្តិឲ្យមាំមួន តាមខទាំង ៩ យ៉ាង ដូចអាត្មាភាពបានអធិប្បាយញែកចេញមកនេះ ប្រទេសរបស់អ្នកក៏នឹងបានសេចក្តីចំរើនសប្បាយយ៉ាងទូលំទូលាយច្រើន គតមានទុក្ខភ័យអ្វីបៀតបៀនបាន ដោយសារតែអ្នក, បើប្រសិនជាកូនកម្ពុជាទាំងឡាយ នៅធ្វើសោះអង្គើយកន្តើយមិនខំខ្មីឃ្មាតគោរពចំពោះជាតិ សាសនា មហាក្សត្រទេ នោះកុំសង្ឃឹមថាប្រទេសយើងនឹងមានដម្លៃស្មើនឹងប្រទេសជាតិដទៃឡើយ ។

ហេតុនេះ សូមឲ្យកូនកម្ពុជាទាំងឡាយ តាំងចិត្តគោរពកលយប់ព្រឹក ប្រឹងស្មៀតប្រឹងគំនិតគិតជានិច្ចជាអាលដ្ឋ ចំពោះជាតិ សាសនា

មហាក្សត្រ របស់យើង កុំឲ្យមានលោះពេលវេលាឡើយ, ប៉ុន្តែមានជនជាតិខ្មែរខ្លះមិនតាំងចិត្តគោរពនោះ បែរទៅជាមានចិត្តក្បត់ទៅវិញ, បើដូច្នេះ តើជាតិប្រទេសរបស់យើងនឹងថ្កើងអំពីផ្លូវណា? ។

កូនកម្ពុជាគោងអ្នកសង្កេតគ្រប់គ្នា ឲ្យឃើញជាក់ច្បាស់ទៅចុះ កុំនៅទ្រមក់ពួនតែខ្លួនយកសុខផ្ទាល់ខ្លួនតែម្នាក់ឯង: ឃើញទេជាតិដទៃដែលគេបានសេចក្ដីសុខ-ចំរើន មកអំពីគេមិនដេកធ្មេចដូចយើងៗគួរក្រោកកំណើត ហើយកុំនៅដេកលក់ដល់ណាទៀត ។

កូនកម្ពុជាទាំងឡាយ! បើអ្នកចង់ឲ្យប្រទេសរបស់អ្នករុងរឿងទៅថ្ងៃមុខ គោងអ្នកខំផ្ចុំក្បាលបណ្ដុះពូជពោលគឺវិជ្ជាចំណេះ ដែលបុគ្គលត្រូវស្វែងរករៀនសូត្រក្នុងលោក មិនត្រូវដំអក់ទំនេទ្រមឹងទ្រមើយមិនបើកភ្នែកមើលទេ ព្រោះកម្ពុជរដ្ឋពជឆាទី អស់លោកពង្សការធំៗ បានបន្ទុំវិជ្ជាក៏ព្រោងព្រាត ត្រូវកូនកម្ពុជា ខំនាំគ្នាធ្វើតែរៀនសូត្រឡើង កុំស្ទាក់ស្ទើរដល់ណាទៀត ។ កូនកម្ពុជាទាំងឡាយ! អ្នកគង់យល់ច្បាស់ថា "ពោះរស់ពីប៉ាយ" ពង្រកាយនេះហើយដែលជាជម្រកសម្រាប់ផ្ទុកវិជ្ជាសព្វគ្រប់ប្រការ ប្រសិនណាជារូបនេះ ដល់នូវភាពវិកលវិការជាបដល់ស្មាំងស្មូមទាំងសង្ខារហើយ បុគ្គលមិនបានព្យាយាម ព្យាបាលបរិហារទេ ចំណេះវិជ្ជាគ្រប់យ៉ាងក៏មិនបេះ ។

យើងបានដឹងជាក់ថា រូបនេះរស់ដោយអាហារពិត ថាបើមិនគិតរកចំណោះទេ បើពេកពេកមកប្រជុំរំខូរពុំរបេះ ពិតជាមាត់លិខូផេះមិនខែលងឡើយ ។

ត្រង់ន័យនេះ សូមបញ្ជាក់ថា មានជនចំពូកខ្លះ ស្នេហានឹងនគរកាយរបស់ខ្លួនដែរ តែដំអក់ទំរន់មិនចំរៀនវិជ្ជាមិនចំការពារទេ ទុកបណ្ដោយឲ្យនគរកាយរបស់ខ្លួននៅជាល្ងង់ខ្លៅធ្លាក់ទៅជាខ្ញុំគេ តែមានចិត្តនោះពុះក្ដៅទៅដោយអំណាចបក្កិលេសទាំង ១៦ ប្រការ នឹងអកុសលចេតសិក ១៤ ប្រការ ជាមេបណ្ដាលដឹកនាំមនុស្សឲ្យប្រព្រឹត្តល្មើស នាំឲ្យជ្រុលប្រពាលអន្ទះសា នាំឲ្យប្រាថ្នាធំហួសហេតុ ទៅជាចង់សោយរាជ្យជាស្ដេច នេះដោយអំណាចសេចក្ដីល្ងង់ខ្លៅ ។ ខ្លះទៅជាចោរប្រព្រឹត្តប្លន់ប្រព្រួត បង្កើតធ្វើទំពតាំងគួរបស់ខ្លួនគនឹងម្ចាស់ផែនដី ខ្លះទៅជាធ្វើឲ្យកើតកលិយុគ ចាក់រុករករឿងរកហេតុ ធ្វើឲ្យពួករដ្ឋបាលកើតសេចក្ដីរំខាន ទាំងនេះព្រោះសេចក្ដីល្ងង់ខ្លៅ គឺអវិជ្ជាពបាំងបិទមិនឲ្យគិតពិចារណាឃើញល្អបាន បែរទៅជាវង្វេងវល់ចិត្តឥតបេះស្បាង កសាងតែបាបកម្មសព្វឥតស្កប់ស្កោះ ធ្វើឲ្យទើសទាស់អំពលចិត្ត រូបតែដល់ពងកាយថែមទៀត ក្លាយទៅជាជាប់ទោសដល់ព្រៃឱ្យ ហ្នឹងហើយផលនៃសេចក្ដីល្ងង់ខ្លៅ ដែលជាផលនាំឲ្យខាតបង់ប្រយោជន៍ក្នុងលោកនេះ លុះដល់ទម្លាយពងកាយអំពីលោកនេះទៅ នឹងនាំប្រាណឲ្យទៅជ្រកកេអបាយមិនខាន ។

ហេតុនេះ កូនកម្ពុជាទាំងឡាយ មិនត្រូវប្រមាទមើលងាយសាសនា មហាក្សត្រទេ ត្រូវតែគោរពប្រណិប័តន៍ ថ្វាយបង្គំរលឹករាល់យប់ថ្ងៃ ទើបពេញជាអ្នកមានកតញ្ញូកតវេទីចំពោះសាសនា មហាក្សត្រមែន ព្រោះព្រះអង្គជាបុព្វការីលើមន្ត្រីនិងប្រជារាស្ត្រទាំងអស់ ព្រមទាំងមានទសពិធរាជធម៌ទាំង ១០ យ៉ាងនិងព្រហ្មវិហារ ៤ ជាប្រមុខរបស់ទ្រង់ បានជាមាននាមប្រាកដថា (រាជូបការោ) ទ្រង់ចាត់ថាជាបុព្វការី ។

សេចក្តីដែលបានរៀបរាប់មកខាងលើនេះ ជាឈ្មោះនៃពាក្យថា សាសនា មានដំឡៃថ្លៃថ្នូរថ្លៃថ្លា សម្មតា សន្មតថាចប់ដោយសង្ខេបប៉ុណ្ណេះ ឯវំ ។

ចប់

ស៊ូឱ្យគេសរសើរ ប្រសើរជាងឱ្យគេអាណិត
ស៊ូឱ្យគេថាមានចិត្ត ប្រសើរជាងគេថាខ្ជិល

យូរ អ៊ុន

# ការប្រើអក្សរខ្មែរ

## ដោយ គិត-ពិន

*ប្រៃសណីយ៍និងទូរគមនាគមន៍ មេមត់ រៀបរៀង*

---

ធម្មតា អក្សរជាតិជនក្នុងលោកដែលទឹងបានចំរើនរុងរឿង ហើយថ្លៃថ្នូរនោះអាស្រ័យមកពីជនរួមជាតិនិយមប្រើ និយមរចនាវិចិត្រឲ្យមានលំអឡើង ហើយយកចិត្តទុកដាក់ ប្រើឲ្យមានរបៀបរៀបរយទៅតាមសម័យលោកនិយម ។

ពាក្យពោលថា "អក្សរខ្មែរ ពិបាកប្រើពេក ចេះផងប្រើផងគក្លិកក្លក់ច្រើនណាស់" ។ ពាក្យនេះជាពាក្យទាល់ប្រាជ្ញ ដោយសារតែខ្លួនមិនចេះហើយក៏ថាទៅ ជាពាក្យពួកជនដែលពុំមានសេចក្ដីស្រឡាញ់អក្សរសាស្ត្ររបស់ខ្លួន ទាំងពុំមានសេចក្ដីស្នេហាជាតិ សាសនារបស់ខ្លួន ជាជនដេកចាំដកដង្ហើមតាមគេ ដេកផ្សងចាំព្រេងសំណាង ។

តាមពិតអក្សរខ្មែរយើងពុំមែនជាពិបាកប្រើទេ អ្នកដែលថាពិបាកប្រើនោះ មកពីអ្នកនោះឯងខ្វះសេចក្ដីចេះដឹងក្នុងរបៀបប្រើអក្សររបស់ខ្លួនឲ្យបានរៀបរយសមរម្យទៅតាមសម័យនោះឯង ។

ក្នុងការប្រើអក្សរជាតិយើង យើងគួរយកលំនាំអក្សរបារាំងសែសជារបៀប ព្រោះអក្សរជាតិបារាំងនេះចំរើនរុងរឿងជាងគេក្នុងលោក ហើយយើងក៏ធ្លាប់បានឃើញ បានប្រើ បានទាំងសរសើរថា សម-ល្អ ថាថ្លៃថ្នូរជាច្រើនឆ្នាំណាស់មកហើយ ។

ការប្រើអក្សរជាតិយើងឲ្យទាន់សម័យនោះ, មុនដំបូងបង្អស់យើងត្រូវពេះប្រើនៅលើស្រោមសំបុត្រ ដែលយើងតែងផ្ញើទៅ-មកជារឿយៗ តាមប៉ុស្តិ៍ ប្រៃសណីយ៍ ទៅញាតិ-មិត្តយើង ព្រោះក្រសួងប្រៃសណីយ៍នេះ ជាទីចលនាចេញចូលនូវសំបុត្រស្នាម ដែលមានអក្សរសាស្ត្រគ្រប់ជាតិទាំងអស់ក្នុងសកលលោក បានចារនៅលើស្រោម ហើយមានរបៀបយ៉ាងប្លែកៗ ជាច្រើនយ៉ាងច្រើនបែប ។

អក្សរដែលចារនៅលើស្រោមសំបុត្រ ជារូបនិមិត្តរបស់អក្សរដែលនៅក្នុងស្រោមនោះឯង គឺថា បើអក្សរនឹងពាក្យនៅលើស្រោមមានសេចក្ដីរៀបរយល្អ មានរបៀបល្អ អក្សរនឹងពាក្យដែលនៅខាងក្នុងស្រោមក៏មានសេចក្ដីនឹងរបៀបរៀបរយល្អដែរ ។ បើខាងក្រៅពុំមានរបៀបល្អទេនោះខាងក្នុងក៏អាចឲ្យគេសន្និដ្ឋានបានជាមិនល្អដែរ ។ ឯពាក្យថាល្អៗក្នុងទីនេះ ពុំបានបំណងយកតួអក្សរល្អជាទីតាំងទេ គឺយករបៀបល្អជាគោល ។

សូមអធិប្បាយយ៉ាងខ្លីៗ អំពីស្រោមសំបុត្រ នឹងរបៀបការស្រោមដូចតទៅនេះ:—

១ — ស្រោមសំបុត្រ — តាមរបៀបធម្មតា ស្រោមសំបុត្រដែលយកឲ្យសមល្អ គឺមានរាងបួនជ្រុងទ្រវែង បណ្ដោយប្រវែង ១៤ សង់ទីម៉ែត្រ ទទឹង ១១ សង់ទីម៉ែត្រ (តែគង់មានតូចមានធំខុះ ច្រើន

បែប- យ៉ាង (ស្របតែនឹងចូលចិត្ត) កុំឲ្យតែធំពេកតូចពេក ។ ក្រដាសផ្ញើស្រោម គេត្រូវចៀសវាង ក្រដាសដែលក្រាស់ឬរឹងពេក និងក្រដាសសសុទ្ធ ឬ ដែលមានបន្ទាត់ខ្វាត់ខ្វែង ។

២— ការស្រោម.— ការស្រោមសំបុត្រត្រូវសរសេរនឹងទឹកខ្មៅជានិច្ច ហាមកុំឲ្យសរសេរនឹងខ្មៅដៃ ។ ត្រូវចាប់សរសេរពីពាក់កណ្ដាលស្រោមចុះមកក្រោម ត្រូវដាក់នាមនឹងនាទីលំនៅយ៉ាងជាក់លាក់នៃអ្នកដែលយើងផ្ញើព្រមទាំងឈ្មោះ ដំបន់ ប៉ុស្តិ៍ប្រៃសណីយ៍នាទីនោះផង ។ សំបុត្រផ្ញើតាមប៉ុស្ត ត្រូវយកឈ្មោះប៉ុស្តជាប្រធាន លើឈ្មោះស្រុកភូមិ ដ្បិតប៉ុស្តជាទីចាត់ការក្នុងកិច្ចនេះ ។ ប៉ុន្តែឈ្មោះប៉ុស្ត និងឈ្មោះស្រុកច្រើនតែស្របត្រូវគ្នា ស្ទើរតែទាំងអស់ តែគង់មានខ្លះខុសគ្នាដែរ ដូចយ៉ាងស្រុកស្ទឹងត្រែង (កំពង់ចាម) ប៉ុស្តិ៍ប្រៃសណីយ៍ហៅព្រែកកក់ ។ សំបុត្រដែលការខ្វង ដាក់ស្រុកស្ទឹងត្រែង ពុំបានដាក់ប៉ុស្តិ៍ព្រែកកក់ផងនោះ ច្រើនច្រឡំហួសរហូតដល់ស្ទឹងត្រែងឯណោះ ទំរាំនឹងបានមកដល់ទីកន្លែងដើមវិញ ត្រូវខាតពេលអស់ប្រហែលជាដប់ថ្ងៃ នឹងបន្ទោសនរណាក៏ពុំបាន ព្រោះជាការច្រឡំនាំឲ្យខកដំណឹងទេឥតការ ។

ចំណែកនាមនឹងទីលំនៅនៃយើងអ្នកផ្ញើត្រូវដាក់កាត់យ៉ាងខ្លី នៅខាងលើពីខាងមុខឬពីខាងខ្នងស្រោមក៏បាន ប្រយោជន៍ដើម្បីបើសំបុត្រនោះទៅមិនដល់បុគ្គលឈ្មោះពុំឃើញ គេនឹងផ្ញើត្រឡប់មកយើងជាម្ចាស់ដើមវិញ ។

តែបើត្រូវចំខាងលើពីខាងមុខស្រោមជានិច្ច ហើយបើយកឲ្យសមល្អ ត្រូវចំនៅជ្រុងខាងស្តាំ ត្រូវចំជុំគ្នាតែកន្លែងមួយ កុំចំរាយឯណេះមួយឯណោះមួយឡើយ ដើម្បីឲ្យប៉ុស្តិ៍ងាយនឹងបោះត្រាសម្គាប់ផង ឲ្យមានកន្លែងទំនេរល្អមើលផង នៅលើកន្លែងទំនេរនេះ គេនឹងបោះត្រាមួយទៀតជានិច្ច ដែលអ្នកទទួលសំបុត្រអាចដឹងថាសំបុត្រនេះ ដាក់ប៉ុស្តិ៍នៅម៉ោងប៉ុណ្ណោះ ថ្ងៃនេះ ខែនេះ ឆ្នាំនេះជាដើម ។

ឯពាក្យត្រូវប្រើក្នុងរបៀបការស្រោមនោះ ត្រូវកុំប្រើពាក្យខុសលំទោន, ពាក្យគួរសមឬពាក្យដែលឥតប្រយោជន៍ឲ្យសោះ ត្រូវប្រើតែពាក្យយ៉ាងងាយហើយបានការជានិច្ច ។

## កុំកាស្រោមដូចខាងក្រោមនេះ:

សូមអាណិតមេត្តាបញ្ជូនសំបុត្រនេះឲ្យដល់ទៅឈ្មោះ
មាស-ចន នៅឃុំកំពង់ស្វាយ ស្រុកស៊ីសុផុន ខែត្រ
បាត់ដំបង ឲ្យបានជាប្រញាប់ៗ ផង

ការស្រោមបែបនេះ សូម្បីស្រោមទាំងមូលក៏ស្មើរតែដាក់ពាក្យទាំងនេះមិនអស់ បើដាក់អស់គង់គ្មានកន្លែងនឹងបិទតែមប្រិ៍ បើបិទបានក៏គ្មានរបៀប ។ ពាក្យ "សូមអាណិតមេត្តាបញ្ជូនសំបុត្រនេះ" ជាពាក្យសាបរលាបច្រើនឥតប្រយោជន៍ ។ យើងពុំបាច់សូមមេត្តាអំពីអ្នកណាទេ បើត្រូវការផ្ញើសំបុត្រគ្រាន់តែទិញតែមប្រិ៍ ១៛៥០ បិទដាក់ប៉ុស្តិ៍ទៅក៏រួចគ្នាស្រេច ។ ប្រាក់ ១៛៥០ នេះជាថ្លៃឈ្នួលសំបុត្រយើង ដែលគេត្រូវតែផ្ញើឲ្យយើងដល់ទីកន្លែងខានមិនបាន ។

ពាក្យថា "ប្រញាប់ៗ" នេះ ក៏គ្មានបានផលអ្វី ក្រៅពីគ្រាន់តែច្រើនឥតការ ហើយនាំតែឲ្យគេជិនឆ្អន់ ។ សំបុត្រដាក់ប៉ុស្តិ៍មិនត្រូវប្រញាប់ជាង កប៉ាល់ ឡាន ឬយន្តហោះ ដែលតែងតែធ្វើចលនាបើកបរហោះហើរសព្វទីកន្លែងរាល់ៗថ្ងៃនោះទេ ព្រោះសំបុត្រគេត្រូវចាត់ផ្ញើតាមយានទាំងនេះឯង ។

សូមកែរបៀបការស្រោមខាងលើនោះដូច្នេះវិញ :—

លោក មាស-បង

ឃុំកំពង់ស្វាយ - ស៊ីសុផុន

បាត់ដំបង

បាត់ដំបងដាក់ក៏បានមិនដាក់ក៏បាន ព្រោះជាឈ្មោះបន្ទាប់បន្សំទេ ហើយសូមកុំគិតខ្លាចថាប៉ុស្តិ៍មិនស្គាល់ ស៊ីសុផុននោះ ។

របៀបការស្រោមមានច្រើនបែបច្រើនយ៉ាងណាស់ក្នុងទីនេះ ខ្ញុំពុំអាចដំកបបានសព្វគ្រប់ទេ ទាំងគំរូការស្រោមក៏ពុំបានយកមកបង្ហាញជូនមើលដែរ ព្រោះយល់ថាអស់លោកគង់ធ្លាប់បានប្រទះឃើញពុំខាន ហើយការធ្វើសំបុត្រនេះមិនមែនជាការក្រទេ គឺគ្រាន់តែបានឃើញក៏អាចយល់បានធ្វើកើតដោយងាយ ។

## ភាសាសជាតិ មារយាទសព្វជ

អក្សរដែលគេបានចារនៅលើស្រោមនេះ ទុកដូចជាភាសា ហើយសជាតិបានចារថ្ងៃថ្នូរ ជារុងរឿងមានអារ្យធម៌ចំរើនថ្កុំថ្កើង ឬគ្មានថយអាប់ឱនយ៉ាងណាបានដែរ ។

ចំណែកស្រោមសំបុត្រវិញទុកដូចជាមារយាទដែលអាចសព្វជ នៃជនអ្នកប្រើប្រាស់ ជាមានសេចក្តីចេះដឹងច្រើន មានមារយាទរម្យទមល្អ មានរបៀបរៀបរយល្អ ឬក៏មានមារយាទអាក្រក់មិនសមសួន ។ល។ ជាដើម ។

ហេតុការណ៍ដូចពោលមកនេះ តើពាក្យថា "អក្សរសាស្ត្រជាគោលចារិករបស់ជាតិ" នោះនឹងមានសេចក្តីសំខាន់ទូលំទូលាយយ៉ាងណាទៅ ក្នុងកិច្ចដែលត្រូវប្រើអក្សរជាតិនេះ ? ។

តាមពិត ស្រោមសំបុត្រ ១ ដែលជនម្នាក់បានចារជាអក្សរជាតិនៅលើនោះ ទោះជាមានរបៀបអាក្រក់ក្តី ល្អក្តី ក៏ពុំអាចឲ្យផលអាក្រក់ ឬផលល្អ ដល់ជនទាំងនគរបានឡើយ ។ ន័យនេះត្រូវយកភាគច្រើនជាប្រមាណគឺថាបើបេះមានភាគច្រើន ត្រូវថាបេះ បើល្អមានភាគច្រើនត្រូវថាល្អ ។

ដូច្នេះ ធម៌សាមគ្គី នឹងមានប្រយោជន៍សំខាន់ដូចម្តេចខ្លះក្នុងរឿងនេះ?

ធម៌សាមគ្គីជាកម្លាំងធំបំផុត គឺបើសាមគ្គីរួបរួមគ្នាជីកទន្លេនឹងបានកើតជាទន្លេ, បើរួបរួមគ្នាជួសជុលប្រាសាទនគរវត្តឲ្យបានគង់វង់ត្រាយរីងដំហារទៅអនាគត នោះនឹងបានសម្រេចជាពុំខាន ។ បើរួបរួមគ្នាកសាងអក្សរសាស្ត្រ គឺយើងមានធម៌សាមគ្គីព្រមព្រៀងគ្នាប្រើអក្សរជាតិយើងវិញ តើអក្សរសាស្ត្រជាតិយើងនឹងមានរស្មីរុងរឿងស្ថិតស្ថេរបេរកាលទៅអនាគត ឬយ៉ាងណា? ។

សូមជនអ្នកស្រឡាញ់អក្សរសាស្ត្រ អ្នកស្រឡាញ់ជាតិសាសនាវិទិប្ប័យ!!! ។

---

# រឿងគ្រូសាញ់អ្នកការទាំងពុកោ

លោក ផេង-ជ្រឹវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែនិងរៀបរៀង

(តពីរឿងអាយោនទាហានចាស់)

---

ក្នុងកាលដ៏កន្លងអន្លែងទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាមព្រះបាទរត្តា ។ ព្រះអង្គតែងព្រួយព្រះរាជហឫទ័យជានិច្ច ព្រោះក្នុងរាជ្យព្រះអង្គ ពួកយក្សបានឆក់យកព្រះអាទិត្យព្រះចន្ទពីលើមេឃទៅបាត់ ។

ព្រះមហាក្សត្រតែងញុាំងរាជបុរសឲ្យប៉ាវគងទូងកេរ គ្រប់ស្រុកគ្រប់ភូមិថា បើឈ្មោះណាអាចធ្វើដូចម្តេចយកព្រះអាទិត្យព្រះចន្ទពីកណ្តាប់ដៃយក្សមកបាន នោះព្រះអង្គនឹងប្រទានព្រះរាជធីតាឲ្យធ្វើជាភរិយា បែងព្រះរដ្ឋជាពីរភាគ ហើយចែក១ភាគឲ្យទៀត, ប៉ុន្តែបើឈ្មោះណាហ៊ានទទួលបំពេញកិច្ចនេះ ហើយធ្វើការមិនសម្រេចវិញ នោះត្រូវយកទោសដល់ប្រហារជីវិត ។

មានអ្នកហាវហានជាច្រើនរូប បានល្បងបំពេញកិច្ចដ៏ក្លាហាននេះ ៗ ប៉ុន្តែវេលាចាប់ធ្វើការ គេរកមធ្យោបាយនឹងធ្វើពុំកើត ខំប្រឹងស្ទុះចុះស្ទុះឡើងរកផ្លូវទៅច្បាំងនឹងយក្សមិនកើត ។ ចំណែកព្រះមហាក្សត្រទ្រង់កាន់ពាក្យសត្យជានិច្ច ។

សម័យមួយ អ្នកហាវហានឈ្មោះគ្រូសាញ់ លុះបានដឹងព្រះរាជបំណងដូច្នោះ ក៏គិតពិចារណានូវរឿងនេះអស់អំឡុងដ៏យូរ ៗ លុះទីបំផុត

មានសេចក្ដីទុកចិត្តក្នុងជំនួយនៃព្រះជាម្ចាស់ និងសេចក្ដីអង់អាចនៃខ្លួន គាត់ប្រថុយទៅយកអាសានៃព្រះចៅផែនដី ។

ទៅតាមផ្លូវ គាត់បានប្រទះមនុស្សពីរនាក់ដែលរាជបុរសនាំយកទៅកាន់ព្រះបរមរាជវាំងដើម្បីនឹងសម្លាប់ ពីព្រោះគេបានរត់បោលព្រះរាជាដែលកំពុងច្បាំងតដៃនឹងពួកយក្ស ។ អ្នកទោសទាំងពីរព្រួយពេកមុខស្រងូត ។ បានឃើញដូច្នោះ គ្រួសាញ់ប្រើបិយវាចាដើម្បីលួងលោមអ្នកទាំងពីរ ហើយនិយាយប្រាប់ថា ត្រូវឲ្យមានសេចក្ដីក្លាហានឡើងវិញ ព្រោះគ្រួសាញ់ឆ្លាតក្នុងការនិយាយណាស់ សំដីផ្អែមដូចស្ករ ។

ការជួបនឹងមនុស្សពីរនាក់នេះ នាំឲ្យគាត់មានសេចក្ដីសង្ឃឹមហើយគិតទុកថា "អញផ្សងសំណាងមើល ។ បើអាត្មាអញសុំទោសឲ្យមនុស្សពីរនាក់នេះ ពីព្រះករុណាបាន នោះអញក៏ត្រូវហ៊ានប្រថុយបំពេញកិច្ចដទៃទៀត, បើមិនដូច្នោះទេ អញត្រូវបំផ្លាញខ្លួន ដោយត្រូវវិលទៅផ្ទះវិញ ។ ធ្វើដូច្នេះទើបល្អ មិនត្រូវបំផ្លាញខ្លួនដោយការពិសោធន៍ឥតប្រយោជន៍" ។

កំពុងវិតក្កក្នុងចិត្តគិតចុះឡើង គាត់បានទៅដល់ព្រះរាជដំណាក់ គ្រួសាញ់ចូលគាល់ព្រះមហាក្សត្រ ហើយបេះក្រាបទូលពីនេះពីនោះ ដោយការប្រើសំដីដ៏ពីរោះ ទាល់តែព្រះរាជាទ្រង់ជ្រាបដោយព្រះអង្គឯងថាទ្រង់ជាបុគ្គលអសប្បុរស បើសម្លាប់អ្នកទោសពីរនាក់នេះ, បើទុកជា

ទៅ នឹងបានកើតមនុស្សជាពលរដ្ឋពីរនាក់ បើទ្រង់ឥតព្រះមេត្តា នោះនឹងហាក្តីតឲ្យមានកេរ្តិ៍អាក្រក់ដល់រូបទ្រង់ទៀត ។

បុរសកំសត់ទាំងពីរនាក់ លុះបានដឹងថាគ្រូសាញ់សុំឲ្យខ្លួនបានរួចពីទោសកាលណា ក៏មានសេចក្តីត្រេកអរក្រៃប្រៀបគ្មាន ។ គេសូមអរគុណជាអនេកអនេកដល់គាត់ ហើយសូមយកជីវិតរបស់គេទៅបួរជួយបំពេញមហន្តកិច្ចរបស់គាត់ ហើយសូមស្បថស្បែនៅចំពោះមុខកណ្តាលទេព្តា ។

ជ័យជំនះទីមួយរបស់គាត់ជាប្រផលដ៏ប្រពៃ ដែលនាំគ្រូសាញ់ហ៊ានចូលទៅគាល់ព្រះរាជាជាថ្មីម្តងទៀត ហើយក្រាបបង្គំទូលដូច្នេះថា: បពិត្រព្រះសម្មតិទេពដ៏ទ្រង់នូវតេជានុភាព សូមព្រះអង្គទ្រង់ជាសុខក្សេមសិរីរាជសម្បត្តិអស់កាលជាយូរអង្វែងតទៅ ។ បានឮថា មានពួកអ្នកហាវហានជាច្រើនរូប ខំយកចិត្តទុកដាក់ដើម្បីដណ្តើមព្រះអាទិត្យនឹងព្រះចន្ទពីក្រុងអសុរិន្ទ ហើយបានត្រូវស្លាប់ខ្លួនអស់ដោយការបំពេញករណីយកិច្ចមិនសម្រេច ។ បពិត្រព្រះទ្រង់យស ទូលព្រះបង្គំមានបំណងចង់ផ្សងវាសនាម្តងមើល ក្នុងការស្វះស្វែងដើម្បីរកចាប់ពួកអាចិត្តមោហាទាំងនោះ ។ ដោយអាស្រ័យជំនួយនៃព្រះជាម្ចាស់ ប្រហែលទូលព្រះបង្គំអាចនឹងសម្រេចជាក់ទណ្ឌកម្ម ដល់ពួកយក្សទាំងនោះ ព្រោះតែចិត្តព្រហើនកោងកាចរបស់វាជាមិនខាន ។ តើព្រះករុណាថ្លៃវិសេសនឹងមានព្រះហឫទ័យមេត្តាករុណាចំពោះទូលព្រះបង្គំផងឬដូចម្តេច ? ។

ព្រះរាជាមានព្រះរាជឱង្ការថា៖ ម្នាលត្រសាញ់! យើងនឹងមិនអាចផ្លាស់ប្ដូរនូវសេចក្ដីសម្រេចរបស់យើងតែមួយបន្ទាត់ ឬបន្តិចក៏ពុំបាន ។ ពាក្យទាំងនោះគឺជាការដាច់ស្រេចឥតវែរុះ ព្រោះយើងជាអ្នកកាន់ពាក្យសត្យ ។ យើងចង់ឲ្យព្រះរាជបញ្ញាយើងតាំងនៅ មានតម្លៃស្មើគ្នា ទាំងផ្ទៃដែនព្រះរដ្ឋ ។ យើងមិនចង់ឲ្យមានការជំទិតស្និតរវាងយើងឡើយ ។

បានឃើញសេចក្ដីសម្រេចនោះ ពាក្យសត្យនៃព្រះរាជានឹងព្រះរាជបំណាងដែលបន្ទន់មិនបានដូច្នោះ ត្រសាញ់ក្រាបទូលដោយសំដីក្លាហានថា៖ បពិត្រព្រះករុណាវិសេស សូមព្រះរាជបំណាងសម្រេចចុះ? ទោះបីបើទូលព្រះបង្គំដឹងថា សេចក្ដីស្លាប់ដេញតាមកិតពីក្រោយក៏ដោយ ក៏ទូលព្រះបង្គំមិនថយរួញរាឡើយ មុនដែលមិនទាន់បានបំពេញឲ្យដល់ទីបំផុតនូវករណីយកិច្ចដែលត្រូវធ្វើដោយសេចក្ដីពេញចិត្តនេះ ។

លុះបានចុះខសន្យាទៅវិញទៅមក រវាងព្រះរាជានឹងត្រសាញ់ហើយ គាត់នៅពីរបីថ្ងៃក្នុងព្រះរាជធានី ដើម្បីរៀបចំប្រដាប់ប្រដានឹងធ្វើការជំនុំឲ្យប្រកបដោយសិរីសួស្ដី រួចទើបគាត់ធ្វើដំណើរចេញទៅ ។

ត្រសាញ់នាំប្អូនរបស់គាត់ទៅផង ។ ជនទាំងពីរត្រាច់ទៅអស់កាលដ៏យូរ កាត់ព្រៃ កាត់ភ្នំ ឆ្លងទន្លេបឹងបួ ហើយបានដល់ផ្ទះជាងដែកមួយជាសំឡាញ់គាត់គឺជាជាងឆ្លាតវៃបំផុតលើផែនដី ថែមទាំងជាអ្នកចេះខាងមន្តវិជ្ជាធ្មប់បន្តិចផង ។ បងប្អូនពីរនាក់ឈប់នៅទីនោះអស់បីថ្ងៃបី

យប់ រួចគ្រសាញ់ទាំងជាងដែក ចូលក្នុងបន្ទប់មួយតែពីរនាក់ ហើយជំនុំធ្វើកតិកាសញ្ញានឹងគ្នា ៗ ព្រឹកស្អែកឡើង ជនជាបងប្អូនក៏បន្តដំណើរទៅទៀត ៗ ចំណែកជាងដែក គិតតែធ្វើរូបតំណាងរូបគ្រសាញ់មួយពីដែកហើយយកទៅដាក់ក្នុងភ្នើង សប់ឲ្យឡើងក្រហមទាំងយប់ទាំងថ្ងៃឥតឈប់ឈរ ៗ

គ្រសាញ់និងប្អូន ដើរទៅៗបានដល់ផ្លូវបំបែកមួយ នាំគ្នាឈប់បរិភោគអាហារដែលនៅសល់ រួចក៏បែកគ្នា យំសោកជូតក្រេង ៗ មុននឹងធ្វើដំណើរចេញ បងប្អូនប្ដូរកូនកន្សែងគ្នា ហើយមានពាក្យថា កាលណាកូនកន្សែងដៃរហែកតែជាយទេ យើងទាំងពីរនាក់តោងមានសេចក្ដីសង្ឃឹមថា នឹងអាចបានជួបគ្នាវិញ បើកាលណាកូនកន្សែងរហែកចំកណ្ដាលគឺអ្នកណាមួយស្លាប់ហើយ ៗ គេយកកាំបិតស្នៀតមួយ ដាក់ទុកក្នុងដីទៀត ហើយមានសេចក្ដីថា: បើអ្នកណាត្រឡប់មកមុន ហើយដកកាំបិតឡើងឃើញមានច្រែះ នោះមិនត្រូវឈប់ចាំឡើយ ប្រាកដជាអ្នកម្នាក់ទៀតស្លាប់ហើយ ៗ រួចពីនោះ គ្រសាញ់ទៅតាមផ្លូវខាងស្ដាំ ប្អូនទៅតាមផ្លូវខាងឆ្វេង ៗ

ប្អូនគ្រសាញ់ ខាងក្រោយដែលបានដើរត្រាច់ចុះឡើងឥតប្រយោជន៍អស់អំឡុងដ៏យូរ ក៏ត្រឡប់មកផ្លូវបំបែកវិញ ដកកាំបិតមើលឃើញគ្មានរទិតអ្វីសោះ ហើយរង់ចាំបងនៅទីនោះ ដោយសេចក្ដីរីករាយរកអ្វីប្រៀប

គ្មាន ។ ឧបមាដូចជាគេបានឃើញព្រះអាទិត្យនិងព្រះចន្ទមកប៉ះនៅឰដី លើមេឃជាថ្មីឡើងវិញ ។

ចំណែកគ្រួសារ ដើរទៅៗ តាមផ្លូវតែមួយ ក៏បានដល់នគរ ស្ដេចយក្សដែលតាំងនៅកន្លែងបំផុតនៃផែនដី ។ ឃើញដូច្នោះ គាត់ សូត្រអាគមន៍ លោតប៉ះដង និម្មិតខ្លួនជាព្រាបតាមសេចក្ដីបង្គាប់របស់ជាង ដែកផែនដី រួចហើរទៅទំលើដើមឈើមួយ ជុះអំពីមុខប្រាសាទយក្ស ។

ពេលនោះ កូនស្រីច្បងរបស់យក្សចេញមក ឃើញព្រាប ហើយ ចូលទៅវិញភ្លាម និយាយប្រាប់ម្ដាយ និងប្អូនស្រីរាឲ្យចេញទៅមើល បក្សីល្អអស្ចារ្យ ។

ប្អូនស្រីរានិយាយថា: នែលោកម្ដាយ! នែអ្នកបង! បក្សីល្អនេះ បើតាមយោបល់ខ្ញុំ គឺដូចជាប្រផ្លូលអកុសលដល់ប្រាសាទយើង ។ ភ្នែក វាដូចជាមិនប្រចាំទឹងភ្នែកបក្សីធម្មតា គឺដូចជាភ្នែកគ្រួសារសក់ក្រហម ។ បើពិតដូច្នោះមែន សេចក្ដីអន្តរាយរបស់យើងមកដល់ហើយ ឥ! ពី ពេលនេះទៅ សូមព្រះជាម្ចាស់ករុណាគិតមេត្តាដល់យើងនិងក្រុមញាតិរបស់ យើងផង ។ ដ្បិតពួកយក្សទាំងប៉ុន្មានមិនមែនជាមិនដឹងសេចក្ដីហាវ ហានរបស់គ្រួសារឡើយ ។

មេយក្ខិនីទាំងបីអង្គ ត្រឡប់ចូលទៅក្នុងប្រាសាទវិញ ដើម្បី ពិចារណាគ្នា ។ គ្រួសារលោតប៉ះដងក្រឡាខ្លួនជាវុយ ហើរចូល

តាមមេឃក្ដីទីក្នុងបន្ទប់ លបបំពួនខ្លួនដំឡូពិតាន ក្នុងក្រហែងផ្កាន ហើយស្តាប់ពួកនិយាយប្រឹក្សាគ្នាអំពីអ្វីទាំងអស់ ។ បានស្តាប់ព្រួសព្វគ្រប់ហើយ គាត់ត្រឡប់ចេញមកវិញ ធ្វើដំណើរទៅព្រៃបែតង ក្លែងខ្លួនជាមនុស្សទៀងវិញ ហើយចូលពួនបាំនៅក្រោមស្ពានមួយ ។

ឥឡូវនេះ គាត់ដឹងច្បាស់ថា ពួកយក្សទាំងឡាយទៅបរបាញ់ក្នុងព្រៃបែតង ហើយវិលត្រឡប់មកវិញ ខ្លះពេលព្រលប់ ខ្លះកណ្ដាលអធ្រាត្រ ចំណែកក្រុងអសុរិន្ទ ស្ដេចយក្ស ពេលសងកើតជិតព្រះអរុណរះ ។

មិនយូរប៉ុន្មាន ក្រឡេកពីក្រោមស្ពានទៅ គ្រសាញ់ឃើញកូនយក្សដែលក្មេងជាងគេមកដល់ ប៉ុន្តែសេះដែលវាជិះ លុះជិតនឹងចុងស្ពាន ស្រែកកញ្ជ្រៀវលោតថយក្រោយប្រាំពីរជំហាន ។ កូនយក្សខឹងណាស់ ស្រែកថា: យី! ចចកបំរុងនឹងស៊ីសេះ? អញគ្មាននរណាមកធ្វើឲ្យភ័យឡើយក្នុងលោកនេះ ក្រែងតែគ្រសាញ់ ។ សូម្បីគ្រសាញ់ក៏ដោយ ក៏ស៊ុះនឹងដៃអញមិនរួចដែរ ។

បានឮដូច្នោះ គ្រសាញ់ឡើងឈរលើស្ពានហើយស្រែកថា: ម្នាលចោរចង្រៃ អាឯងមកដល់ហើយ ? យើងច្បាំងគ្នាដោយអាវុធឬលេងនឹងដៃទទេ ? ។ ដោយដៃទទេ គឺត្រឹមត្រូវល្អ ។

ជនទាំងពីរចាប់ចោកគ្នាទៅវិញទៅមក ។ យក្សចាប់គ្រសាញ់លើកឡើង បុកចុះទៅក្នុងដីកប់ដល់ជង្គង់ ។ ចំណែកគ្រសាញ់ចាប់យក្ស

លើកម្ដងវិញ  បុកកប់ចុះដល់កហើយយកដាវកាត់ត្រឹមក្បាល ៗ រួចចាប់ខ្មោចយក្សបោលទៅក្រោមស្ពាន  គាត់ឈប់សម្រាកបន្តិច ៗ

ដល់កណ្ដាលអធ្រាត្រ  យក្សមួយទៀតមកក្ដាម  ម្ដងនេះលោកថយក្រោយដប់ប្រាំពីរជំហាន  រាដេវ  ហើយនិយាយដូចយក្សជាប្អូនទៀត ៗ  គ្រសាញ់ស្ទុះចេញមកឆ្លើយដូចមុន  ហើយចាប់តយុទ្ធគ្នា ៗ

យក្សនេះចាប់លើកគ្រសាញ់បុកចុះទៅក្នុងដីលិចដល់ចង្កេះ ៗ ប៉ុន្តែគ្រសាញ់បម្រះស្ទុះងើបឡើងយ៉ាងរហ័ស  ហើយចាប់យក្សបុកលិចត្រឹមករួចយកដាវកាត់កម៉ាត់ ៗ  គាត់បោះខ្មោចយក្សទីងខ្មោចសេះ  ឲ្យទៅជួបគ្នានៅឯក្រោមស្ពានទៀត ៗ

លុះសងកើត  ម្ដងនេះមែនទែនហើយ ៗ  ក្រុងអសុរិន្ទជិះលើសេះងងឹតមេឃផាយមកពីនាយ ៗ  លុះរៀបជួងស្ពាន  សេះលោតចិតសិបជំហានថយក្រោយ ៗ  ខឹងក្រពេក  រើងបន្តិចបន្តួចនេះហាក់ដូចជាការណ៍ដ៏សំខាន់អស្ចារ្យ  ក្រុងអសុរិន្ទស្រែកគ្រហឹមថា : យ៉! ចចកចង់ស៊ីសេះ ? អញគ្មានខ្លាចអ្នកណា ទាំងអស់នៅលើផែនដី  វៀវលែងតែគ្រសាញ់សក់ក្រហម ៗ ហើយគ្រសាញ់ហ្នឹងទៀតសោត  អញសំឡឹងឲ្យបំពៅលែងតែមួយព្រួញក៏ទីងសូន្យជីវិត ៗ

(មានត)

## ការបណ្ដុះនិស្ស័យ

## ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

៥ — ចិត្តប្រកបដោយយុត្តិធម៌.— បានដល់ចិត្តដែលប្រកបដោយធម៌ទៀងត្រង់ រក្សាសិទ្ធិអំណាចដែលត្រូវតាមធម៌ ក្នុងចំណែកគួរបានគួរមានរបស់មនុស្ស ធ្វើឲ្យអ្នកបានអ្នកមានពេញចិត្ត ដោយឃើញថាជាការស្មើភាគគ្នា សមគួរដល់ចំណែកដែលខ្លួនគួរបានគួរមាន ប្រាសចាកការកិកកក់ខ្ពស់ទាប ដែលជាហេតុឲ្យកើតទោមនស្សតូចចិត្ត ឬ អៀនខ្មាសចំពោះគ្នានឹងគ្នា នេះជាការយុត្តិធម៌ ។ ការយុត្តិធម៌ដែលពិតប្រាកដនោះ ត្រូវប្រកបដោយអង្គគឺ ការទៀងត្រង់ ការត្រឹមត្រូវតាមធម៌ និងការដឹងទាន់ នេះជាអង្គនៃសេចក្ដីយុត្តិធម៌ ។

អង្គគឺការទៀងត្រង់ ជាគោលត្រូវមានដល់អ្នកដែលមានចំណែកគួរបានគួរមាន ។ អង្គគឺការត្រឹមត្រូវតាមធម៌និងការដឹងទាន់ ជាគោលត្រូវមានដល់អ្នកមេចំណែក ដែលត្រូវបែងចែកឲ្យត្រឹមត្រូវដល់បុគ្គលដែលមានសិទ្ធិគួរបាន ទទួលតាមចំណែករបស់ខ្លួន ។ អង្គទាំង ៣ នេះ ជារនាំងដែកនៃយុត្តិធម៌ អាចការពារភ័យបានល្អបំផុត ។ នៅខាង

ក្រោមម្លប់នៃសេចក្ដីយុត្តិធម៌ដែលប្រកបព្រមដោយអង្គ ៣ នេះ នឹងមិនមាននរណាជាមនុស្សវៀចវេរ នឹងមិនមាននរណាត្រូវរងអំពើអយុត្តិធម៌ឡើយ ។

ចិត្តដែលប្រកបដោយយុត្តិធម៌នោះ ជាចិត្តអាចប្រសិទ្ធិសេចក្ដីទៀងត្រង់ឲ្យដល់អ្នកដទៃ ជាគោលសន្តិសុខនៃពួកគណៈ ជាម្លប់ពោធិ៍ ម្លប់ជ្រៃ ដែលអ្នកក្ដៅចូលមកជ្រកបានត្រជាក់ ។ បើមាននាទីគ្រប់គ្រងមនុស្ស ក៏គ្រប់គ្រងដោយមនោសិទ្ធិ នឹងមនោរសជ្ឈា គឺដៃឆ្វេងកាន់ស្បោងប្រាក់ ដៃស្ដាំកាន់រំពាត់ ។ បើនឹងធ្វើទោសដល់អ្នកខុស ក៏គិតពិចារណាអង្កេតការណ៍ច្រើនលើកសិន ។ សូម្បីនឹងឲ្យបំណាច់រង្វាន់ដល់អ្នកធ្វើត្រូវ ក៏សាកសួរថ្លឹងមើល លៃមើល ឲ្យទាល់តែចិត្តយល់ច្បាស់សិន ។ មិនគ្រប់គ្រងដោយមនោបុទ្ធិនឹងអាជ្ញាសិទ្ធិ គឺដៃឆ្វេងកាន់ផារ ដៃស្ដាំកាន់លំពែងដែលជាការមានតែសត្រូវទាំងអស់ ។

បើមាននាទីជាក្រុមសំរាត់ ឬ សួរចម្លើយ ចំពោះអ្នកដែលមានកំហុសក្នុងព្រះរាជបញ្ញត្តិច្បាប់ទំលាប់ ក៏មិនក្លែងធ្វើការដែលមិនគួរធ្វើ ឬវៀរការដែលមិនគួរវៀរ មិនជួយអ្នកខុសឲ្យរួចចាកអាជ្ញា មិនក្លែងធ្វើឲ្យអ្នកឥតខុសទទួលអាជ្ញា ឬឲ្យអ្នកខុសតិចទទួលអាជ្ញាច្រើនហួសកំហុស ។ សូម្បីមាននាទីខាងតុលាការ ក៏ធ្វើការកាត់ក្ដីដោយប្រយ័ត្នប្រយែង មិនប្រើអំណាចឲ្យខុសច្បាប់ដោយឃើញសំណូក ដូចជាមិនទារសំណូក មិន

ទទួលសំណូក ក្នុងកាលដែលមានគេមកសូក ទោះជាសំណូកនោះធ្វើឲ្យចម្រើនដល់ខ្លួនក៏ដោយ ឬក៏ប្ដេជ្ញាចិត្តថា នឹងមិនទទួលសំណូកជាអាណាប្រយោជន៍ផ្ទាល់ខ្លួន ៗ មនុស្សថោកទាប ក៏រមែងបានទទួលសេចក្ដីករុណា ដែលគេគ្មានទឹកសង្ឃឹមថានឹងបានទទួលសោះ ៗ សូម្បីអ្នកសូកសម្ព ក៏ខ្លួនមិនក្លែងដាក់ទោស ព្រោះឃើញថា ជាអ្នកមានសម្បត្តិដើម្បីឲ្យគេសូកដែរ ៗ មនុស្សបែបនេះឯងជាគោលនៃការរៀបរយត្រជាក់ត្រជុំ ជាទីសុខសម្រាន្តក្រៃលែងរបស់ប្រទេសជាតិ ៗ

អ្នកមានចិត្តប្រកបដោយយុត្តិធម៌ សូម្បីមានអំណាចក៏នៅតែប្រើអំណាចត្រូវតាមខែត្រដែន ទំលាក់អំណាចរបស់ខ្លួនចេញ មិនគ្រាន់តែថាមានអំណាចហើយ ក៏សង្កត់សង្កិនទៅទាល់តែហួសហេតុនោះឡើយ ដូចជានាយភ្នាក់ងារដែលប្រើអំណាចក្នុងដំណែងខុសច្បាប់ នឹងអ្នកដែលមាននាទីខាងការថែរក្សាសុខនឹងរម្ងាប់ទុក្ខរបស់ប្រជារាស្ត្រ ត្រឡប់ជាប្រើអំណាចរបជាន់បង្អាប់កំហែងឲ្យគេឲ្យឬឲ្យគេរកទ្រព្យឬផលប្រយោជន៍ដែលខុសទំនងមកឲ្យខ្លួន ធ្វើការសង្កត់សង្កិនពលរដ្ឋឲ្យបានសេចក្ដីក្ដៅក្រហាយ ធ្វើដោយល្មើសច្បាប់ បង្គាប់ឲ្យគេខូចទ្រព្យ ប្រាក់ មាស ដោយឥតហេតុ នឹងលំអៀងទៅក្នុងអគតិ ឃើញថាច្បាប់ឲ្យដាក់ទោសហើយ ក៏គិតតែពីដាក់តាមអំពើចិត្ត, រឿងក្ដីឬកិច្ចការដទៃទៀត ដែលគួរធ្វើហើយក្សាម ក៏ក្លែងធ្វើឲ្យយឺតយូរ ធ្វើឲ្យប្រជារាស្ត្រខកខានខាតការងារអាជីវៈដែលជាគ្រឿងចំរើនដល់ប្រទេសជាតិ ៗ

មនុស្សអយុត្តិធម៌ មនុស្សចិត្តអាក្រក់នឹងមនុស្សល្ងង់ ចាត់ជាកេត របស់ជាតិ ព្រោះអាចធ្វើឲ្យប្រទេសជាតិ កើតវិកវចលាចល ដែលដើម ក្ដៅក្រហាយ ។ អ្នកប្រើអំណាចខុសធម៌ មើលងាយជះជាន់គេឲ្យវិនាសទឹងក្ដៅក្រហាយយ៉ាងនេះ ឈ្មោះថាដុតលោកឲ្យឆេះ ។ មិនតែប៉ុណ្ណោះឡើយថែមទាំងដុតខ្លួនឯងឲ្យវិនាសផង ព្រោះនឹងត្រូវទទួលអំណាចបែបនោះមកវិញ ក្នុងកាលដែលខ្លួនអស់អំណាច ដូចពស់វែកដែលត្រូវស្រមោចស៊ីវិញ ក្នុងកាលដែលរាថយកំឡាំងដូច្នោះ ។ "ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី" នេះជាដម្រាបុរាណ ចូរចាំឲ្យជាក់ ។

លោក-អ្នកប្រុសស្រីទាំងឡាយ ត្រូវកុំធ្វើដូចគេទាំងនោះឡើយ ទោះជាតាំងនៅក្នុងដំណែងនាទីបែបណាក៏ដោយ ក៏គួរតែមានចិត្តប្រកបដោយយុត្តិធម៌ ធ្វើការឲ្យត្រឹមត្រូវតាមទំនងនីតិធម៌ នឹងប្រតិបត្តិឲ្យត្រូវតាមមុខក្រសួងរបស់ខ្លួនដោយសុចរិត ត្រូវធ្វើឲ្យសមគួរដល់ចិត្តគេចិត្តយើង ស្រឡាញ់មិត្តកក្តិក្នុងលោកឲ្យដូចជាស្រឡាញ់ខ្លួន ។ អំពើណាដែលគេធ្វើមកលើយើងៗមិនពេញចិត្ត យើងមិនត្រូវធ្វើអំពើនោះដល់គេឡើយ លុះតែអំពើណាដែលគេធ្វើមកលើយើងៗពេញចិត្ត សឹមយើងធ្វើអំពើៈនោះតបទៅគេវិញ ។ សេចក្ដីល្អ សេចក្ដីត្រូវនោះទៀត បើទុកជាលោក-អ្នកខំធ្វើទៅហើយ ត្រឡប់ជាបានអន្តរាយ បានគាប់

ខូចមុខមាត់ បានទទួលភ័យ បានទទួលទុក្ខទោសដល់ជីវិត បានទទួលការទើសទាក់ នឹងបានទទួលពាក្យដំនៀលថាជាមនុស្សអាក្រក់ក៏ដោយ ក៏កុំលះបង់សេចក្ដីល្អ សេចក្ដីត្រូវនោះពោលឡើយ គួរប្រតិបត្តិឲ្យមាំទាំចំពោះវត្ថុដែលត្រូវធម៌ ។ សូម្បីសេចក្ដីល្អរបស់មនុស្សដទៃ ក៏ជាកិច្ចដែលលោកអ្នកគួរនឹកដល់ នឹកឲ្យត្រូវធម៌ ដើម្បីរក្សាសិទ្ធិគន្លងផ្លូវល្អដែលគេគួរបាន ដូចជារបស់ណាមួយដែលជាប់ទាក់ទងនឹងលោក-អ្នក បើតាមផ្លូវយុត្តិធម៌ ត្រូវបានទៅគេ តែគេលំបាកយក ព្រោះនៅជាប់ទាក់ទងក្នុងអំណាចរបស់លោក-អ្នក ឬអ្នកដទៃ ក៏លោកអ្នកគួរតែរកវិធីដែលនឹងឲ្យគេបានទទួលវត្ថុនោះដោយស្រួលឡើង ។

អត្ថនៃសេចក្ដីល្អដែលគួរឲ្យដល់សត្រូវ គឺកុំប្រកាន់ទោស ដែលគួរឲ្យដល់មិត្ត គឺចងមិត្តភាពឲ្យស្និទ្ធ, ដែលគួរឲ្យដល់ខ្លួនឯង គឺកេរ្តិ៍ឈ្មោះ ហើយដែលគួរឲ្យដល់មនុស្សទូទៅ គឺចិត្តប្រកបដោយយុត្តិធម៌ ។ ដូច្នេះ លោក-អ្នក ចូរយកឈ្នះមនុស្សក្រោធដោយមិនក្រោធតប, ផ្ចាញ់មនុស្សមិនល្អ ដោយធ្វើល្អតប, រម្ងាប់ពៀរចេញ ដោយមិនចងពៀរចុះ, ព្រោះវិធីនេះ ជាគន្លងផ្លូវនៃយុត្តិធម៌ មិនមែនជាវិធីធ្វើឲ្យទោសចំរើនឡើងដោយការធ្វើអាក្រក់តបនឹងអាក្រក់ទេ គឺជាវិធីតបតនឹងសេចក្ដីអាក្រក់ដោយសេចក្ដីល្អ ។

លក្ខណៈចិត្តសុភាព ៥ ប្រការនេះ រមែងធ្វើភាពជាមនុស្សសុខសម្រាន្តរុងរឿងឲ្យសម្រេច នាំឲ្យមនុស្សចេះគិតជួយមិត្តភក្ដិផងគ្នាឲ្យ

ផុតចាកទុក្ខភ័យ ផ្តុងផ្តើមសេចក្តីចំរើនរបស់ពួកគណៈឲ្យចំរើនក្រៃលែងឡើង នឹងចងភ្ជាប់សេចក្តីព្រមព្រៀងគ្នាឲ្យជាប់នៅក្នុងសន្តិសុខ ។ ក្នុងទីណាមានសេចក្តីវិនាសអន្តរាយ ឬសេចក្តីលង់ខ្លៅ ឬក៏សេចក្តីទីទាល់ក្រលំបាក ត្រដាបត្រដួស អ្នកដែលមានចិត្តសុភាព រមែងបញ្ចូនដៃចូលទៅជួយគេក្នុងទីនោះ ព្រោះការបានឃើញគេមានទុក្ខភ័យ ឬបានឮសំឡេងគេស្រែកថ្ងូរនោះ ជាការដែលនាំឲ្យរន្ធត់ដល់ចិត្តរបស់អ្នកសុភាព ។ ទឹកដែលថ្លាបំផុតគឺទឹកចិត្ត ។ ដូច្នេះ អ្នកមានទឹកចិត្តសុភាព ទើបត្រាំនៅស្ងៀមពុំបាន ខំប្រញាប់ប្រញាល់បញ្ចូនអធ្យាស្រ័យមេត្រី ចូលទៅជួយភ្លាមៗ ធ្វើឲ្យអ្នកមានទុក្ខកើតសេចក្តីកក់ក្តៅចិត្តនឹងមានសេចក្តីរីករាយ បំបាត់ទុក្ខទៅបានដូចជាពន្លឺភ្លឺរុងរឿងដែលចូលទៅក្នុងបន្ទប់ អាចកំចាត់ងងឹតចេញបានដូច្នោះ ។

ចិត្តសុភាពជាចិត្តខ្ពស់ សូម្បីមេឃដែលថាខ្ពស់ ក៏នៅតែទាបជាងចិត្តសុភាព ។ ចិត្តសុភាពនេះជាឫសគល់នៃសេចក្តីសុភាពទាំងពួង ។ ព្រោះថាកាលបើចិត្តសុភាពហើយ រមែងនាំឲ្យកាយវាចាសុភាពតាម បើចិត្តខូច កាយវាចាក៏ខូចតាមដែរ បើទុកជាខំក្លែងធ្វើកិរិយានិងវាចាឲ្យសុភាពយ៉ាងណាក៏ដោយ ក៏គង់មិនផុតពីពាក្យថា "ខាងក្នុងដំបៅ ខាងក្រៅសះជា" ឬថា "ខាងក្រៅរលង់ ខាងក្នុងៈលួយ" ឬក៏ថា "ចិត្តជាទេវទត្ត មាត់ជាទេវតា" ។ ព្រោះការក្លែងធ្វើឲ្យសុភាពតែខាងក្រៅ

មិនមែនសុភាពចេញមកអំពីទឹកចិត្ត គង់តែធ្លាក់ទៅក្នុងភាពជាអ្នកមានចិត្តខូច អាចឲ្យកើតទោសក្នុងខាងក្រោយបាន ដូចក្នុងជម្រាមួយថា:

កាលពីមុន ទឹកថាមាស ជម្ពូទេ
ជាតិបរិសុទ្ធ ដូចសាច់មាស ទឹកប្រាំបី
លុះដេញទៅ ស្រាប់តែឃើញ ខុសប្រក្រតី
ទើបដឹងថ្មី ថាជាតួជ នៃទង់ដែង ។

មនុស្សចិត្តសុភាព រមែងមានភូមិធម៌ជាទីអាស្រ័យ មិនឃើញចំពោះតែសេចក្ដីសុខ សេចក្ដីចំរើនចំណែកខ្លួនម្យ៉ាងទេ រមែងសំឡឹងឃើញដល់សេចក្ដីសុខ សេចក្ដីចម្រើនរបស់អ្នកឯទៀតផង ប្រើកាលវេលាក្នុង ១ ជីវិត ធ្វើតែសេចក្ដីល្អ ដើម្បីសេចក្ដីស្ងប់ចំពោះខ្លួននិងមនុស្សទាំងមូល សូម្បីនៅក្នុងស្រុកតូចៗ ក៏គង់ប្រសើរជាងមនុស្សមានចិត្តជាទាសៈថោកទាបដែលសម្ងំនៅក្នុងស្រុកធំៗ ។ ព្រោះសេចក្ដីវិនាសនិងការមិនរៀបរយ រមែងកើតមកតែអំពីមនុស្សចិត្តអាក្រក់ម្យ៉ាង ។ ចំណែកសេចក្ដីចំរើននិងការស្ងប់រៀបរយ ទើបកើតមកតែអំពីមនុស្សចិត្តសុភាព ។ បើលោក អ្នកមានចិត្តសុភាពហើយ លោក-អ្នកនឹងអាចលើកស្ទួយថ្កើមប្រមាត់របស់ប្រទេសជាតិ ឲ្យខ្ពស់ក្រៃលែងឡើងបាន ទាំងបានឈ្មោះថាជាអ្នកធ្វើគុណយ៉ាងធំបំផុតឲ្យដល់ប្រទេសជាតិ ។ ដូច្នេះ ការរំលាយចិត្តអាក្រក់ ឲ្យក្លាយទៅជាចិត្តសុភាព ឲ្យក្លាយទៅជាចិត្តខ្ពស់ ឲ្យក្លាយ

ទៅជាចិត្តមានប្រយោជន៍ ទើបជានាទីដែលយើងត្រូវតែយកចិត្តទុកដាក់ធ្វើឲ្យណាស់ ដើម្បីធ្វើសន្តិសុខឲ្យកើតមានឡើងក្នុងលោកនេះ ។

កិរិយាសុភាព, វាចាសុភាព និងចិត្តសុភាព ចាត់ថាជាខ្លឹមសារយ៉ាងសំខាន់ របស់និស្ស័យសុភាព ។ តែគោលធំបំផុតរបស់និស្ស័យសុភាពនោះ នៅត្រង់ចិត្តសុភាព ដែលមានការស្ងប់ស្ងៀម, ឧបអរសាទរ, ឃើញចិត្តគេចិត្តឯង, និងខ្លួនខ្ចាប់ខ្លួន និងមានយុត្តិធម៌ជាលក្ខណៈ ។ លក្ខណៈទាំងនេះ ជាគេជះដែលអាចធ្វើឲ្យមនុស្សនិស្ស័យសុភាពមានដំឡៃ បណ្តាលឲ្យអ្នកដទៃមានសេចក្តីនិយមរាប់អានឡើង ។

ពិតមែនហើយ! អ្នកធំនឹងមានដំឡៃបាន ព្រោះតែមានអ្នកតូចនិយមរាប់អាន ។ អ្នកតូចនឹងមានដំឡៃបាន ព្រោះតែមានអ្នកធំអាណិតអាសូរ ។ គ្រូនឹងមានដំឡៃ ព្រោះតែមានសិស្សស្រឡាញ់ ។ ខ្ញុំរាជការនឹងមានដំឡៃ ព្រោះតែមានប្រជាជនចូលចិត្តនឹងទុកចិត្តចំពោះការរាជការនោះ ។ អ្នកសរសេរ អ្នកនិពន្ធ នឹងមានដំឡៃ មានកេរ្តិ៍ឈ្មោះ ព្រោះតែរឿងរបស់ខ្លួននោះ មានអ្នកអាននិយមចូលចិត្តច្រើន ។ កាលបើយើងមិននិយមក្នុងមិត្តភក្តិៗ ក៏គ្មានដំឡៃ ។ សូម្បីមិត្តភក្តិមិននិយមចូលចិត្តចំពោះខ្លួនយើង ព្រោះយើងគ្មានគ្រឿងល្អឲ្យគេចូលចិត្តបាននោះ យើងក៏ទៅជាមនុស្សអស់ដំឡៃ គ្មានគេចូលចិត្ត ។ នេះជារឿងពិត ដែលផុសចេញមកពាក់សេចក្តីពិត ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ១១

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាំងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ខណៈនោះ តាំងស៊ុនទីងអៀវហានរត់ទៅដល់តំបន់ ១ ក៏ឲ្យតែងព្រះតម្រាប់ព្រះចៅហៀនតេ ២ ច្បាប់ គឺ ១ ច្បាប់ជាសេចក្ដីល្បួងលួងលោមលីឈុយ គុយតី,១ ច្បាប់ទៀតឲ្យទៅដល់ហាន់សៀម លីផ៉ាក់ ទីងហោ-តាយ ៣ នាយនេះជាពួកចោរនៅដែនស្រុកហោតាំង ។ សេចក្ដីសំបុត្រនោះថា ទ្រង់ឲ្យលើកទោសហើយ ឲ្យអ្នកទាំង ៣ នាំយកបក្សពួកមកបំរុងទទួលស្ដេចទៅឯស្រុកហោតាំង ។ ឯហាន់សៀម លីផ៉ាក់ ទីងហោតាយ បានទទួលព្រះតម្រាស់នោះហើយ ក៏លើកបក្សពួកមកក្រាបបង្គំគាល់ ។ តាំងស៊ុនឃើញពួកចោរមកដល់ក៏ប្រឹក្សាថា យើងទីងលើក

កងទ័ពត្រឡប់ទៅវាយយកស្រុកហង្សាវិញ ឲ្យបានជាទីមាំសិន រួចសឹមគិតការតទៅ ។ នាយចោរទាំង ៣ នាក់ ក៏ស្ម័គ្រចូលចិត្តព្រមផង តាំងស៊ុនក៏លើកកងទ័ពត្រឡប់ជាមួយនឹងព្រះចៅហៀនតេ មកប្រទល់នឹងកងទ័ពលីឈុយ គុយគី ។ ឯលីឈុយ គុយគី កាលលើកទ័ពទៅតាមនោះ លុះដល់ទៅទីតំបន់ណាក៏ឲ្យទាហានរឹបកេតត្បាតពិឃាដមនុស្សចាស់ជរាជាច្រើន ណាដែលមានកំលាំងខ្លាំងពូកែក៏ឲ្យយកទុកជាទាហាន ហើយឲ្យឈ្មោះថា ពួកមិនខ្លាចស្លាប់ ។

កាលកងទ័ពលីឈុយគុយគីនឹងកងទ័ពតាំងស៊ុន បានជួបប្រទះគ្នានោះនៅតំបន់យូអៀង ។ ទាហានទាំងសងខាងបានតយុទ្ធគ្នាជាយូរថ្ងៃ ។

លីឈុយគុយគីប្រឹក្សាគ្នាថា ឥឡូវនេះ តាំងស៊ុនបានពួកចោរមកធ្វើជាកំលាំងច្រើនណាស់ បើដូច្នេះយើងត្រូវប្រើឧបាយឲ្យទាហានយើងយកអស់របស់ទ្រព្យ នឹងសំពត់អាវសារ៉ៃស្បៃទៅបោះចោលកាយក្បែរផ្លូវ បើពួកចោរបានទៅឃើញ មុខជាមានសេចក្ដីប្រាថ្នាលង់ចិត្តគិតតែរើសយក មិនរាំងខ្លួន យើងត្រូវលើកទាហានទៅព័ទ្ធបង្ក្រាប ហើយចេញមកវាយខ្ទប់ទាំងសងខាង ទ័ពតាំងស៊ុនក៏នឹងអស់ទីអាងបែកបាក់ទៅឯង ។

គុយគីបានស្ដាប់ក៏ចាប់ចិត្តគិតឃើញត្រូវ ទើបចាត់ឲ្យទៅយករបស់ទ្រព្យ នឹងសំពត់សារ៉ៃស្បៃកាយចោលតាមផ្លូវវៀងទៅ ហើយឲ្យ

ទាហានពួនបង្កប់ទាំងសងខាង ។ កងទ័ពពួកចោរឃើញដូច្នោះ ក៏ចេះតែបបួលគ្នាដើររើសយកមិនបានរាំងខ្លួន ។ លីឈុយគុយគីឃើញបានការ ទើបលើកសេនាទាហានចូលវាយចាក់កាប់សម្លាប់កងទ័ពតាំងស៊ុននឹងពួកចោរវិនាសស្លាប់ជាច្រើន ។ លុះតាំងស៊ុននឹងអៀវហាងតទល់ពុំឈ្នះក៏នាំព្រះចៅហៀនតេរត់ទៅទិសឯជើង, លីឈុយគុយគីក៏លើកតាមទៅ ។

លីឆាក់នាយចោរឃើញដូច្នោះ ទើបក្រាបទូលព្រះចៅហៀនតេថា កងទ័ពតាមមកជិតនឹងទាន់ហើយ អញ្ជើញព្រះអង្គទ្រង់ចុះចាកព្រះរាជ-រថាឡើងគង់ព្រះទីនាំងអស្សពាហន៍រត់ទៅមុនចុះ ទូលព្រះបង្គំជាខ្ញុំទាំងពួងនឹងតទល់ការពារពីខាងក្រោយ ។ ព្រះចៅហៀនតេត្រាស់ថា ដែលយើងនឹងរត់ទៅមុននោះមិនគួរទេ បើអ្នកទាំងអស់គ្នានឹងជាប្រការម្តេច យើងក៏ត្រូវដូច្នោះផង ។ នាហ៊ុននឹងនាយចោរទាំងពួង នាំគ្នាទួញយំរំ ហើយក៏ឲ្យទាហានច្បាំងការពារជាលំដាប់ទៅ ។ ហោចាយនាយចោរឃើញកងទ័ពសន្ធាប់តាមមកជិតណាស់ ក៏បរសេះចេញទៅតតាំងរាំងក ។ ទាហានលីឈុយគុយគីបានបាញ់ធ្នូចម្រុះទៅ ត្រូវហោចាយធ្លាក់ពីលើសេះស្លាប់ ។

តាំងស៊ុននឹងអៀវហាងឃើញកងទ័ពជាប់មកជិតណាស់ ក៏អញ្ជើញព្រះចៅហៀនតេនឹងព្រះមហេសីស្រីស្នំរត់ទៅដល់ឆ្នេរស្ទឹងហាងហោ ។

លីង៉ាក់ក៏ចុះទៅមាត់ស្ទឹងប្រឹងរកបានទូក ១ បែរមកចម្លងស្តេចចុះ តែមាត់ច្រាំងនោះខ្ពស់ទ្រទ់ យាងចុះពុំបាន ។ ទាហានលីឈុយគុយតីក៏កាន់តែដេញដិតប្រកិតដល់មាត់ព្រៃ ។ ហ៊ុកតិកជាបងព្រះមហេសីក៏យកព្រៃស្បូត្រនឹងដើមឫស្សី បងព្រះអង្គព្រះចៅហៀនតេនឹងព្រះអគ្គមហេសីយាងចុះទៅដាក់លើទូកបាន, រៀបនឹងច្រានចេញ ពួកនាហ្មឺនទឹងទាហាននោះមិញ ក៏ដណ្តើមគ្នាចុះទៅលើទូករៀបនឹងក្ទូកលិចក្នុងជលធី ។ លីង៉ាក់ដកគ្រឹះកាប់នាហ្មឺនទឹងទាហានស្លាប់ជាច្រើននាក់ ទើបនាំគ្នាចាក់ទូកនោះអណ្តែតចេញទៅដល់ត្រើយម្ខាង ស្តេចក៏យាងឡើងទៅលើមាត់ច្រាំង ហើយតាំងតែទៅមកចម្លងគ្នាជាច្រើនសា មិនទាន់អស់គ្នាទ័ពលីឈុយគុយតីលើកមកដល់ មនុស្សដែលនៅសល់មិនទាន់បានឆ្លង ក៏ស្រែកហៅគ្នាអឺងកងទៅវិញទៅមក ខ្លះស្រែកយំសោករត់ថ្ងេចថ្ងា មុខគួរឲ្យអនិច្ចាកម្មស្តេចនឹងរាស្ត្រត្រូវនិរាសចាកគ្នាក្នុងវេលានោះ ។ អឿវហេងឲ្យស្វែងរករទេះបាន ១ ហើយអញ្ជើញព្រះចៅហៀនតេ នឹងព្រះអគ្គមហេសីស្តេចយាងទៅ ។

នាហ្មឺន ១១ ១២ នាក់នឹងមេចោរពីរនាក់ បាននាំព្រះចៅហៀនតេស្តេចទៅដល់ស្រុកថៃហៀង ទទួលពេលយប់ ក៏បានចូលទៅឈប់សំណាក់ក្នុងរោងគៀង, តាចាស់ជាម្ចាស់រោងនោះបានយកបាយសម្លមកថ្វាយ, ព្រះចៅហៀនតេសោយមិនបាន លុះព្រឹកឡើងស្តេចក៏យាងចាក

ទីនោះ ទទួលចូបប្រទះនឹងអៀវពីវ ដែលជានាហ្មឺនខ្ញុំរាជការជាន់ចាស់ ចូលមកក្រាបសំពះហើយយំសោកា អាណិតអនាថព្រះចៅហៀនគេក្រៃពន់ប្រមាណណាស់ ៗ ហាន់យ៉ុនក្រាបបង្គំទូលថា លីឈុយគុយគីនោះ វមែនជឿស្ដាប់ពាក្យទូលព្រះបង្គំជាខ្ញុំ សុំព្រះអង្គគន់ប្រថាប់នៅទីនេះសិន ទូលព្រះបង្គំជាខ្ញុំនឹងវិលទៅនិយាយទុចុយហាមឃាត់ ឲ្យលើកទ័ពត្រឡប់ទៅវិញឲ្យបាន ៗ ព្រះចៅហៀនគេទ្រង់ព្រះសណ្ដាប់ ទើបត្រាស់តបថា ដែលអ្នកមានសន្ដានអាណិតដល់យើង ទទួលវិលទៅហាមឃាត់លីឈុយគុយគីវេលានេះក៏ទៅចុះ ៗ ហាន់យ៉ុនក្រាបថ្វាយបង្គំលាចេញទៅ ៗ លីឆាក់មិនព្រមស្ដាប់ពាក្យ, ហាន់យ៉ុនទើបរៀបប្រឹនាំស្ដេចទៅដល់តំបន់អានអ៊ឹប ជូនពេលយប់ ក៏អញ្ជើញស្ដេចទៅឈប់កន្លែង ១ ហើយឲ្យមនុស្សទាំងអស់គ្នានោះផ្លាស់វេនយាមរក្សា ៗ

ឯលីឈុយគុយគីកាលលើកទ័ពមកដល់ស៊ួនហង់ហោ ឃើញពួកស្រីស្នំក្រមការនឹងបណ្ដាខ្ញុំរាជការព្រមទាំងពួកខន្ទី ក៏ឲ្យចាប់ខ្លួនឃុំទុកនៅទីនោះ ៗ លុះហាន់យ៉ុនទៅទាន់បាននិយាយហាមឃាត់លីឈុយ-គុយគីថា ដែលលោកលើកញ្ញហៈទ័ពដាប់តាមស្ដេចព្រះចៅហៀនគេមកប្រាថ្នានឹងធ្វើឲ្យអន្ដរាយដល់ព្រះអង្គនោះមិនគួរទេ បណ្ដាពស្ដ្រីទាំងពួងនឹងម,ខសេចក្ដីគរហានិន្ទាបាន លោកចូរលើកសេនាទាហានវិលទៅ

វិញចុះ  បើលោកស្តាប់ពាក្យខ្ញុំ  មនុស្សទាំងពួងនឹងនិយមសរសើរដល់លោកតទៅឯមុខ ៗ លីឈុយគុយគឺបានស្តាប់ក៏ចុះចិត្តថាត្រូវ ទើបបើកលែងនាហ្មឺនខ្ញុំរាជការទាំងក្រុមការស្រីសុំឲ្យចេញទៅទាំងអស់ ៗ ត្រានោះស្រូវថ្លៃណាស់  អាណាប្រជានុរាស្ត្រកើតទុរ្ភិក្សអត់ឃ្លានដាច់ពោះស្លាប់គ្រប់តំបន់ ៗ

គៀវហៀវទៅហ្វាយស្រុកហោឡាយ ហង់អ៊ុបទៅហ្វាយស្រុកហោ-គង់  ដឹងដំណឹងដូច្នោះក៏ចាត់ចែងសំពត់សាវអាវស្បៃនឹងចំណីអាហារនាំយកទៅថ្វាយព្រះចៅហៀនតេ មានព្រះរាជហឫទ័យត្រេកអរណាស់ ៗ ឯតាំងស៊ុននឹងអៀវហង់ប្រឹក្សានឹងបណ្តាខ្ញុំទាំងពួងថា  យើងនឹងឲ្យទាហានទៅធ្វើដំណាក់ក្នុងស្រុកឡូកអៀង  នឹងបានអញ្ជើញស្តេចយាងទៅប្រថាប់ ៗ លីអាក់ឆ្លើយថា ដែលលោកគិតដូច្នេះខ្ញុំមិនយល់ព្រមផងទេ ៗ តាំងស៊ុនតបថា ស្រុកឡូកអៀងនោះជាទីក្រុងមកពីដើមយូរហើយគួរនឹងអញ្ជើញព្រះបាទហៀនតេទៅគង់, ដែលអ្នកនឹងឲ្យតាំងក្រុងទៅទីនេះខ្ញុំឃើញមិនសប្បាយសោះ ៗ លីអាក់និយាយថា បើលោកនឹងអញ្ជើញស្តេចទៅគង់ឯក្រុងឡូកអៀងក៏តាមចិត្តចុះ  តែខ្លួនខ្ញុំនឹងសុំតាំងទ័ពបញ្ជប់នៅតំបន់អានអ៊ុបនេះ ៗ តាំងស៊ុនអៀវហង់ក៏លើកកងទាហាននាំព្រះចៅហៀនតេនឹងព្រះអគ្គមហេសីស្រីព្រះស្នំ ឲ្យឡើងគង់រទេះលើកតម្រង់ទៅស្រុកឡូកអៀង ៗ

ឯលីង៉ាក់ប្រែចិត្តគិតក្បត់ ទើបលបប្រើមនុស្សស្និទ្ធស្នាលឲ្យទៅប្រាប់លីឈុយគុយគីថា "តាំងស៊ុនទីងអៀវហេង នាំយកព្រះចៅហៀនតេទៅស្រុកឡុកអៀង ហើយទីងស៊ុំខ្វះលើកកងទ័ពទៅស្កាត់ចាប់ព្រះចៅហៀនតេសម្លាប់ចេញ ។ លីឈុយគុយគីឮដូច្នោះ ក៏ប្រែត្រឡប់ចិត្តគិតត្រេកអរនាំគ្នាទៅធ្វើការជាមួយ ។

ខណៈនោះតាំងស៊ុនទីងអៀវហេង បានដឹងកិត្តិស័ព្ទថាលីង៉ាក់ប្រែចិត្តក្បត់ ក៏នាំបំរើព្រះចៅហៀនតេទៅទាំងយប់ទាំងថ្ងៃគ្មានឈប់ឈរ ។ លីង៉ាក់ជាមនុស្សលោភៈ មិនរង់ចាំលីឈុយគុយគីឲ្យព្រមគ្នា ម្នីម្នាលើកទាហានរបស់ខ្លួនស្រូតតាមស្ដេចទៅដល់ភ្នំគីសាន់ ជួនពេលយប់ប្រមាណយាមពាក់កណ្ដាលថ្ងាយក៏ទាន់ស្ដេចនៅទីនោះ ។ លីង៉ាក់ក៏ស្ទុះចេញទៅស្រែកឃាត់ជាខ្មោយកលថា នរណាដែលនាំស្ដេចត្រេចទៅនោះ ឲ្យឈប់ពិគ្រោះនិយាយគ្នាសិន ដ្បិតលីឈុយទីងគុយគីលើកទ័ពស្និទ្ធមកពីក្រោយហើយ ។ ព្រះចៅហៀនតេទ្រង់ព្រះសណ្ដាប់ឮច្បាស់ក៏ភោមនស្សព្រួយព្រះទ័យស្លុតព្រះកាយា ។ អៀវហេងក្រាបទូលថា "សំឡេងដែលស្រែកមកនេះចំពោះជាសំឡេងលីង៉ាក់ ជាចោរអ័ប្បល័ក្ខណ៍ក្ងងកលខ្មោយសុំឲ្យព្រះអង្គទ្រង់ស្រូតទៅចុះ" ទូលហើយក៏ចាត់ឲ្យស៊ុយឡងកាថយទៅក្រោយចាំតយុទ្ធគ្នានឹងលីង៉ាក់បាន ៣ ទ្វេង ។ ស៊ុយឡងយកពូថៅកាប់ត្រូវលីង៉ាក់ធ្លាក់ពីលើសេះស្លាប់ ដេញចាក់កាប់សម្លាប់ពួកចោរទាំងនោះវិនាសស្លាប់ជាច្រើន ទើបត្រឡប់តាមស្ដេចទៅទៀត រហូតផុតភ្នំគីសាន់ ។

លុះពេលព្រឹកឡើង ទទួលជួបប្រទះនឹងគៀវអៀននាំយកស្បៀងអាហារចូលមកថ្វាយ ព្រះចៅហៀនតេក៏ទ្រង់រេះរាយទទួល ហើយត្រាស់ឲ្យឡើងទីជាតៃស៊ូ គឺមន្ត្រីធំ ៗ គៀវអៀនក្រាបបង្គំលាទៅវិញ ព្រះចៅហៀនតេក៏លើកចូលទៅក្នុងក្រុងឡុកអៀង ទ្រង់យាងទតឃើញទីព្រះដំណាក់ពន្ធាភាក់ក្នុងព្រះរាជវាំង នឹងតឹកឃ្លាំងរោងទង ផ្ទះសម្បែងអាណាប្រជានុរាស្ត្រផង សឹងតែភ្លើងឆេះវិនាសខ្ចាត់ខ្ចាយអស់ ស្មៅទឹងដើមឈើទាំងឡាយក៏ដុះលូតលាស់ទៅជាព្រៃរហោស្ថាន ៗ ព្រះចៅហៀនតេទប់ពុំបាន ទ្រង់ព្រះកន្សែងសោកពិលាប ព្រះអស្សុជលនេត្រហូរជ្រួតជ្រាបសព្វព្រះកាយ ទ្រង់មានព្រះរាជឧក្ការថា ទីនេះជារបស់ព្រះមហាក្សត្រអំពីបុរាណលោកបានកសាងទុក ជាទីបរមសុខរៀងមកយូរហើយ ម្ដេចឡើយមកវិនាសសាបសូន្យដូច្នេះ ៗ

គ្រានោះ អស់នាហ្មឺនសព្វមុខមន្ត្រីខ្ញុំរាជការ បានចាត់ឲ្យមនុស្សម្នាកាប់ឆ្ការបោសជំរះក្នុងទីបរិវេណវាំងចាស់នោះ ហើយឲ្យរៀបសង់ជាប្រាសាទដំណាក់ខាងមុខខាងក្រោយនឹងទីព្រះរាជរោងរម្យ សម្រាប់ខ្ញុំរាជការតូចធំចូលក្រាបបង្គំគាល់តាមទំនៀម ៗ ឯអាណាប្រជានុរាស្ត្រទាំងឡាយនាំគ្នាខ្វល់ខ្វាយរុះរើផ្ទះសម្បែង ចូលទៅសង់ក្នុងកំពែងក្រុងប្រហែល ៥០០ ខ្នង ៗ

ក្នុងសម័យនោះស្រូវថ្លៃណាស់ អស់បណ្ដារាស្ត្រគ្រប់ស្រុកអត់ឃ្លាន គ្មានស្រូវអង្ករបរិភោគ ដាច់អាហារស្លាប់ច្រើនណាស់ ខ្លះនាំគ្នាទៅដក ឫសស្មៅនូវមើមឈើមកបរិភោគតាងអាហារ បណ្ដាទាហ៊ានតូច-ធំខ្ញុំរាជ-ការទាំងអាណាប្រជារាស្ត្រនៅក្នុងស្រុកឡុកអៀង ខ្លះស្វែងទៅជ្រៀត ជ្រែករកកាប់ទុសបេះស្លឹកឈើនៅក្បែរព្រះតំណាក់ចាស់ ខ្លះជីកគាស់ ដំឡូងក្ដួចក្រោមពានតឹកឃ្លាំងដែលភ្លើងឆេះ ធ្នឹមផ្ទោងផ្ទានពុករបេះបាក់ ធ្លាក់មកត្រូវមនុស្សស្លាប់ជាច្រើន ។

ខណៈនោះអៀវតីវយកសេចក្ដីក្រាបបង្គំទូលព្រះចៅហៀនគេថា ឡាយព្រះហស្ដរបស់ព្រះអង្គ ដែលទ្រង់ប្រគល់ឲ្យទូលព្រះបង្គំជាខ្ញុំទុក-នោះ ក៏មិនទាន់បានយកទៅឲ្យចូឆូនៅឡើយ ។ ព្រះចៅហៀនគេជ្រាប ហើយត្រាស់បង្គាប់អៀវតីវថា: ចូរអ្នកនាំយកទៅឲ្យចូឆូចុះ ដើម្បីនឹងបាន ចូលមកជួយធ្វើរាជការក្រុងអៀវតីវ ចាត់ប្រើបំរើឲ្យនាំឡាយព្រះហស្ដ នោះទៅឲ្យចូឆូៗ ឃើញព្រះសុភអក្សរក៏សោមនស្សត្រេកអរណាស់ ទើប ប្រឹក្សានឹងសេនាទាហានទាំងពួងថា ឥឡូវនេះមានព្រះតំរាស់ត្រាស់ ហៅឲ្យយើងចូលទៅជួយធ្វើរាជការក្នុងក្រុងឡុកអៀងហើយ អ្នកទាំង ឡាយនឹងយល់ឃើញដូចម្ដេច ? ។

(មានត)

# រឿងអារក្សថ្លែងរឿងម្ភៃប្រាំ

## លោកសាង · សាវ៉ាត លេខានុការ ក្រសួងហិរញ្ញវត្ថុ

### ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

## រឿងទី ៤

អារក្សទូលថា: "បពិត្រព្រះមហារាជ! ក្នុងអតីតកាលមានស្តេច ១ ព្រះអង្គព្រះនាមព្រះបាទរូបសេន (Rupsên) សោយរាជ្យនៅទីក្រុងភោគវតី (Bhogavati) ទ្រង់មានសេកមួយឈ្មោះចូរាមាន (chûraman) ។ ថ្ងៃមួយនោះ ព្រះរាជាទ្រង់សួរសេកអំពីវាចេះអ្វីខ្លះ ។ សេកទូលថា: "សូមព្រះបរមរាជទ្រង់ជ្រាប, ទូលព្រះបង្គំចេះទាំងអស់" ។ ព្រះករុណាមានព្រះរាជឱង្ការសួរទៀតថា: "បើឯងស្គាល់ទាំងអស់ដូច្នេះ ចូរឯងប្រាប់អញមើល តើស្រីដែលមានរូបឆោមល្អសក្តិសមនឹងអញមាននៅទីកន្លែងណា?" ។

សេកទូលថា "សូមទ្រង់ជ្រាប! នៅក្នុងស្រុកមាគធី (Magadhi) មានស្តេចមួយអង្គព្រះនាមមាគធេវារ (Magadhevar) ។ ព្រះរាជានេះមានបុត្រីមួយល្អ ហើយមានប្រាជ្ញា ព្រះនាមព្រះនាងចន្ទ្រវតី (ពាក្យក្តិង្គប្រែថា: ព្រះភក្ត្រល្អដូចព្រះចន្ទ្រ) ។ ព្រះនាងនេះហើយដែលព្រះអង្គនឹងបានរៀបអភិសេកជាមួយ" ។ លុះទ្រង់ព្រះសណ្តាប់ពាក្យរបស់

សេកកាលណា ព្រះមហាក្សត្រិយ៍ ទ្រង់ហៅពិជ័យហោរដែលមានឈ្មោះចន្ទ្រក្រាន្ត (chandrakrant) មកហើយទ្រង់សួរថា: "តើខ្ញុំរៀបមង្គលការជាមួយអ្នកណា?" ។ ហោរលុះបើកក្រាំងពិនិត្យស្រេចក៏ទូលយ៉ាងម៉ឺងម៉ាត់ថា: "មាននារីម្នាក់ ឈ្មោះចន្ទ្រវតី គឺនាងនេះហើយដែលព្រះអង្គរៀបអភិសេកជាមួយ" ។ ព្រះរាជាលុះទ្រង់ឮដូច្នោះ ទ្រង់ហៅព្រាហ្មណ៍ម្នាក់មកដល់ ទើបទ្រង់ពន្យល់ព្រាហ្មណ៍នេះសព្វគ្រប់អស់ ហើយមានព្រះបន្ទូលថា: "ចូរឯងទៅជិតស្តេចមាគធេវកុំខាន, ដល់ឯងរៀបចំអាពាហ៍ពិពាហ៍របស់អញរួចហើយ ចូរឯងត្រឡប់មកវិញ, អញនឹងធ្វើឲ្យឯងសប្បាយមិនខានឡើយ" ។ ឯព្រាហ្មណ៍ជារាជទូតនោះក៏ក្រាបបង្គំលាព្រះរាជាចេញទៅ ។

ឯព្រះរាជបុត្រីរបស់ស្តេចមាគធេវ មានសត្វល្វាទេកញីមួយឈ្មោះមទនាមញ្ជរី (Mada-na (Marjiri) ។ ព្រះនាងបានសួរបក្សីដូចស្តេចដែរថា: "ប្រុសឯណាជាប្តីដែលសមនឹងអញ?" ។ សត្វល្វាទេកបានទូលថា: "ស្វាមីរបស់ព្រះនាង គឺព្រះបាទរូបសេនព្រះចៅនៃក្រុងកោត-វតី" ចាប់ដើមពីបានដំណឹងនេះ យុវជនទាំងពីរស្រឡាញ់គ្នាដោយឥតបានឃើញមុខគ្នាសោះ ។

ចំនួនច្រើនថ្ងៃក្រោយមក ព្រាហ្មណ៍រាជទូតបានទៅដល់នគរមាគធ ហើយចូលទៅថ្វាយរាជសាររបស់ម្ចាស់ខ្លួនដល់ព្រះបាទមាគធេវ ។

ទ្រង់ព្រមព្រៀងរៀបរាប់ហមង្គលការព្រះរាជបុត្រីព្រះអង្គ ទើបត្រាស់ហៅព្រាហ្មណ៍ម្នាក់ ក្នុងបណ្ដាព្រាហ្មណ៍ទាំងអស់របស់ព្រះអង្គ មកដល់ហើយទ្រង់ប្រគល់ជំនូនទាំងប៉ុន្មាន ដែលគេធ្លាប់ជូនក្នុងពេលនោះឲ្យទៅព្រាហ្មណ៍នោះ រួចទ្រង់ឲ្យព្រាហ្មណ៍នោះទៅជាមួយនឹងរាជទូតរបស់ព្រះបាទរូបសេន ដោយទ្រង់ត្រាស់ថា: "ចូរឯងទៅថ្វាយសេចក្ដីគោរពរបស់អញដល់ព្រះអង្គផង លុះកាលណាទូលព្រះអង្គថាអញយល់ព្រមថ្វាយព្រះរាជបុត្រីហើយ ត្រូវត្រឡប់មកវិញឲ្យឆាប់ ព្រោះកាលណាឯងមកដល់ភ្លាម អញនឹងរៀបអស់គ្រឿងនៃបុណ្យអាពាហ៍ពិពាហ៍នេះតែម្ដង" ។

ក្រោយមកព្រាហ្មណ៍ទាំងពីរ នាំគ្នាដើរអស់ចំនួនច្រើនថ្ងៃ ទើបបានមកដល់ប្រាសាទព្រះបាទរូបសេន ហើយក៏នាំគ្នាថ្វាយសារដែលខ្លួននាំមកនោះ ដោយរីករាយ ។ ព្រះមហាក្សត្រិយ៍ទ្រង់រៀបចំគ្រឿងប្រដាប់ប្រដា រួចព្រះអង្គទ្រង់យាងទៅកាន់ទីបុណ្យ ។ ទ្រង់យាងទៅដល់ស្រុកនេះចំនួនច្រើនថ្ងៃក្រោយមក ។ លុះអភិសេកនឹងទទួលជំនូនការរួច ទ្រង់សូមលាព្រះបាទមាគធេវរ ហើយយាងត្រឡប់មកទីប្រាសាទរបស់ព្រះអង្គវិញ ។ ចំណែកព្រះនាងឧត្ដមយានីបានដឹកនាំទ្រង់មទនាមញ្ជរី របស់ព្រះនាងមកជាមួយផង ។ ចំនួនច្រើនថ្ងៃមក ជនទាំងអស់ក៏បានមកដល់ប្រទេសរបស់ខ្លួនវិញ ហើយបានរស់នៅយ៉ាងក្សេមក្សាន្តក្នុងដំណាក់របស់ទ្រង់ ។

ថ្ងៃមួយនោះ ទ្រង់សេកនឹងទ្រង់ល្វាបេកញីនៅជិតគ្នាកន្លែងដំណាក់ ។ ព្រះមហាក្សត្រិយ៍នឹងព្រះរាជអគ្គមហេសីទ្រង់ពិភាក្សាគ្នាថា: "គ្មានអ្នកណាមួយនៅម្នាក់ឯងក្នុងទីស្ងប់ស្ងាត់បានទេ. យើងត្រូវផ្សំផ្គុំសេកនឹងល្វាបេក រួចយើងដាក់វាក្នុងទ្រុងតែមួយ ដើម្បីឲ្យវារស់នៅបានសប្បាយផង" ។

ស្ដេចទាំងពីរអង្គទ្រង់ឲ្យគេយកទ្រុងធំមួយមក ឯសេកនឹងល្វាបេកក៏ត្រូវគេដាក់ជាមួយគ្នាទៅ ។

ចំនួនច្រើនថ្ងៃមក គាប់ជួនព្រះមហាក្សត្រិយ៍ នឹងព្រះរាជឯកអគ្គមហេសីទ្រង់ប្រថាប់ដៃកជិតគ្នា ។ សេកនិយាយទៅកាន់ល្វាបេកថា: "ចំណង់ទាំងអស់របស់សេចក្ដីស្នេហា ជាវត្ថុយ៉ាងល្អប្រពៃបំផុតនៅនាលោកិយនេះ បើរូបជនណារស់នៅនាស្ថានកណ្ដាលនេះ ដោយឥតស្គាល់ចំណង់នេះ ជននោះរស់នៅឥតប្រយោជន៍ ហេតុដូច្នេះ ឱល្វាបេកអូន, បងសូមឲ្យនាងព្រមឲ្យបងចងទៅនឹងអូន ដោយចំណង់នេះ?" ។

ប៉ុន្តែមទនាមញ្ញរីឆ្លើយតបវិញថា: "ខ្ញុំគ្មានត្រេកត្រអាលនឹងឈ្មោលណាទេ" ។

ត្លកមាននិយាយឡើងវិញថា: "តើហេតុម្ដេចក៏យ៉ាងដូច្នោះ"? ។ ពីព្រោះប្រុសទាំងអស់ សុទ្ធតែពួកឧក្រិដ្ឋចិត្តមិនត្រង់ ជាមនុស្សក្បត់ជាអ្នកពិឃាតស្រី ។

សេកកាត់ពាក្យថា: "តើស្រីនោះយ៉ាងណា? តើស្រីមិនមែនអ្នកអាក្រក់, អ្នកចិត្តវៀច, អ្នកល្ងង់, អ្នកកំណាញ់ និងអ្នកសម្លាប់ប្រុសដែរឬអី?" ។

ការជជែកគ្នានេះជាហេតុឲ្យសត្វទាំងពីរប្រឈ្មោះគ្នា ។ ឯស្តេចទ្រង់បានសាកសួរអំពីហេតុនៃការឈ្លោះនេះ ។ សត្វល្មាចេកឆ្លើយថា: "ព្រះមហារាជ! មនុស្សប្រុសទាំងអស់ តែងទោរទន់ទៅខាងផ្លូវបាប ហើយសុទ្ធតែជាអ្នកសម្លាប់ស្រី ព្រោះហេតុយ៉ាងនេះហើយ បានជាទូលព្រះបង្គំគ្មានចូលចិត្តនឹងអ្នកណាមួយសោះឡើយ សូមព្រះមហារាជស្តាប់រឿងដែលទូលព្រះបង្គំនិទានថ្វាយដូចតទៅនេះ, រឿងនេះអាចបង្ហាញព្រះអង្គឲ្យទ្រង់យល់ថា "មនុស្សប្រុសតែងប្រព្រឹត្ត ដូចទូលព្រះបង្គំបានរៀបរាប់ទូលព្រះអង្គមិនខាន' ។

នៅក្នុងក្រុងអិលាបុរ: (Ilapur) មានអ្នកជំនួញម្នាក់ឈ្មោះមហាធន (Mahadhan) ប្រែថា មហាសម្បត្តិ ។ ដោយសារគ្មានកូនទៅ អ្នកជំនួញនេះតែងដើរធុតង្គ សូត្រធម៌ មើលគម្ពីរបុរាណ (Puronas) គម្ពីរស្តីអំពីរឿងកកើតភព រឿងវិនាស រឿងចំរើនលោកិយ រឿងទេវតា រឿងព្រះបាទមនុ (Manus) ហើយមានចិត្តជូរទូលាយដល់ព្រាហ្មណ៍ទាំងអស់ ។

នៅចុងក្រោយបង្អស់ កន្លងយូរពីនោះមក, ដោយចំណាន់របស់ព្រះ នាយឈ្មួញបានកូនប្រុសមួយ ។ សេចក្តីសប្បាយទាំងពួងក្នុងការ

ទទួលកំណើតនេះបានមានឡើងយ៉ាងអឹកអធិក? នាយឈ្មួញបានដាក់ទានដល់ព្រាហ្មណ៍និងកវីជាច្រើន ។ ពួកអ្នកក្រីក្រទាំងឡាយ ដែលឃ្លានហើយដែលស្រេក ក៏គ្មានត្រូវក្ដួចឡើយ ។ កាលណាកូននាយឈ្មួញនេះបានអាយុប្រាំឆ្នាំ នាយឈ្មួញបង្រៀនឲ្យមើលអក្សរ ។ ប៉ុន្តែកូននេះ គ្មានរៀនសូត្រទេ គិតតែទៅលេងជាមួយក្មេងឯទៀត ។ លុះកាលណានាយឈ្មួញទទួលមរណភាព ក្រោយពីពេលនោះបន្តិចមក បុរសក៏ទៅជាមេផ្ទះ គិតតែលេងបៀប៉ោកល់ថ្ងៃ ហើយនៅវេលាយប់គិតតែខ្វល់នឹងស្រីញី ។ អាស្រ័យហេតុនេះ ទ្រព្យសម្បត្តិក៏រលាយបន្តិចម្តងៗ ក្នុងចំនួនច្រើនឆ្នាំក្រោយមក ធនធានក៏អស់គ្មានសល់ ។ បុរសចាកចោលស្រុករបស់ខ្លួន ហើយបានទៅដល់ទីក្រុងមួយ ឈ្មោះក្រុងចន្ទបុរៈ (chandrapur) ទីក្រុងព្រះចន្ទ ។

នៅក្នុងទីក្រុងនេះ មាននាយឈ្មួញម្នាក់ ឈ្មោះហេមគុប្ត (Hemgupt) ដែលជាអ្នកមានទ្រព្យ ។ បុរសដើរចូលទៅជិតនាយឈ្មួញនោះ រំលឹកអំពីឈ្មោះឪពុករបស់ខ្លួនប្រាប់ឈ្មួញនោះ ហើយនិយាយអំពីដំណើរការរបស់ខ្លួនផង ។ នាយឈ្មួញសប្បាយចិត្តនឹងស្តាប់បុរសនេះណាស់ ។ គាត់ក្រោកឈរឡើងឱបបុរស ហើយសាកសួរអំពីហេតុដែលបុរសនោះមក ។ ឯបុរសក៏និទានរឿងប្រាប់វិញថា ដល់ខ្លួនផ្ទុកទំនិញដាក់ក្នុងកប៉ាល់រួចកាលណា គាត់ទៅក្នុងកោះមួយដើម្បីធ្វើជំនួញ រួចលុះកាល

ណាលក់ទំនិញអស់ នោះស្រេចគាត់ផ្ទុកទំនិញថ្មីៗ មួយទៀត រួចត្រឡប់ទៅស្រុករបស់គាត់វិញ ។ បុរសនិយាយតទៅទៀតថា: "ប៉ុន្តែស្រាប់តែមានព្យុះមួយក្លាមកក្នុងពេលនោះ ឯនាវារបស់ខ្ញុំក៏បែកបាក់ខ្ទេចខ្ទី ខ្ញុំឱបក្តារមួយសន្ទឹក ទើបខ្ញុំបានមកដល់ទីត្រាំងនេះ ប៉ុន្តែខ្ញុំខ្មាសគេដោយខាតបង់អស់ទំនិញ និងទ្រព្យសម្បត្តិខ្ញុំនេះ តើឲ្យខ្ញុំហ៊ានត្រឡប់ចូលទៅក្នុងស្រុកខ្ញុំវិញ ហើយទៅបង្ហាញមុខយ៉ាងនេះ ដល់អស់ជនដែលខ្ញុំស្គាល់ម្តេចកើត?" ។

ព្រោះសំដីបុរសនិយាយដូច្នោះ អ្នកជំនួញក៏និកថា: អញអង្គុយនៅផ្ទះអញដោយសុខសោះ វាស្នាបានខះខំបណ្តេញនូវអំពល់ទាំងឡាយអំពីរូបអញអស់ ឱកាសដែលលេចឡើងនេះ ជាអំណោយរបស់ទេវតាអាត្មាអញមិនត្រូវបណ្តោយឲ្យឱកាសនោះរបូតផុតទៅវិញទេ, ដូច្នេះគួរតែអញរៀបការកូនអញនឹងបុរសនេះទៅ, ឥឡូវនេះអញនឹងធ្វើតែតាមការណ៍ដែលគេអាចធ្វើបាន ព្រោះថាតើអ្នកណាអាចដឹងថាថ្ងៃក្រោយនោះយ៉ាងណាកើត" ។

លុះគុបគំនិតដូច្នេះហើយ នាយឈ្មួញទៅជិតប្រពន្ធរបស់គាត់ហើយនិយាយថា: "កូនរបស់ឈ្មួញម្នាក់មកដល់ទីនេះ, បើប្អូនសុខចិត្តផងយើងនឹងរៀបការនាងរតនាវតី (Ratnavati) ដែលជាស្រីឡាញ់ត្បូងពេជ្រ, នាងករិយា លុះបានឮក៏រីករាយតែក្នុងចិត្តហើយនិយាយទៅកាន់ប្តីថា:

"ម្នាលអ្នក! កាលណាទេវតាប្រទាន កន្ត្រសំណាងនេះលើផ្លូវដែលអ្នកដើរ ត្រូវតែអ្នកចាប់យកកន្ត្រសំណាងនេះ, បំណងរបស់យើងក៏នឹងបានសម្រេច, កុំចាំអ្វីឲ្យយូរការ យើងទៅនិមន្តលោកមកហើយកំណត់វេលាដែលគតលោកបង្ហាញឲ្យរៀបការបាន" ។ នាយឈ្ពួញបានទៅអញ្ជើញព្រាហ្មណ៍ម្នាក់មក ។ លុះកំណត់ពេលល្អជាស្រេច ទើបឈ្ពួញរៀបអាពាហ៍ពិពាហ៍កូនស្រីឲ្យទៅបុរស ហើយបានទាំងឲ្យចំណងដៃជាច្រើនផង ព្រមទាំងបានឲ្យគ្រួសង្សារថ្មីនេះនៅជាមួយទៀត ។

ក្រោយពីនោះបន្តិចមក កូនរបស់នាយឈ្ពួញនិយាយទៅកាន់គំរិយាថា: "ចំនួនច្រើនថ្ងៃណាស់មកហើយ តាំងតែអំពីបងមកនៅក្នុងស្រុករបស់ប្អូន បងគ្មានបានដំណឹងអ្វីអំពីគ្រួសាររបស់បងសោះ, បងព្រួយចិត្តណាស់, ឥឡូវប្អូនដឹងភាពសតិរបស់បងហើយ ចូរប្អូនទៅជំរាបម្តាយប្អូនផង ដើម្បីឲ្យលោកយល់ព្រមឲ្យបងទៅ បងនឹងទៅស្រុករបស់បងវិញ, ហើយបើប្អូនចង់ ប្អូនជូនបងទៅផង" ។ រគនារីនិយាយប្រាប់ម្តាយរបស់ខ្លួនថា: "ប្តីរបស់ខ្ញុំចង់ទៅស្រុករបស់គេ សូមកុំឲ្យអ្នកម្តាយព្រួយ" ។

ឯមាតានេះ ក៏ទៅជិតប្តីរបស់ខ្លួន ហើយបញ្ជូនពាក្យសុំរបស់កូនប្រសាខ្លួន ។ ឯនាយឈ្ពួញ លុះឮដូច្នោះ ឆ្លើយថា: "មានអ្វី! យើងឲ្យវាទៅ ព្រោះយើងគ្មានអំណាចអ្វី ទៅលើកូនរបស់គេទេ យើង

បំពេញតាមចំណង់ ។" ។ លុះកាលណាហៅកូនស្រីរបស់ខ្លួនមកហើយ និយាយថា: "ចូរឯងប្រាប់យោបល់ឯងមកអញមើល ! តើឯងចង់ទៅផ្ទះឪពុកក្មេកឯងឬទេ? ឬមួយឯងចូលចិត្តនៅជាមួយម្តាយឯង? ។ នាងក៏កក្តាំងអស់ស្មារតី ឥតឆ្លើយអ្វីឡើយ ប៉ុន្តែលុះកាលណា នាងទៅជិតប្តីនាង នាងនិយាយថា "ឪពុកនឹងម្តាយខ្ញុំសន្យា ធ្វើតាមចិត្តបងចង់ទាំងអស់ ប៉ុន្តែសូមបងកុំទោលប្អូនឲ្យសោះ" ។

ដល់ចុងបង្អស់មក នាយឈ្មួញបានហៅកូនប្រសារបស់ខ្លួនមកឲ្យច្បាប់ទៅ ដោយបានឲ្យរទេះគោស្នងមួយទៅនាងជាបុត្រីផង ព្រមទាំងខ្ញុំកំដរផង ជនទាំងពីរចេញដំណើរទៅ ។

មិនយូរប៉ុន្មាន ជនទាំងពីរនេះ បានទៅដល់ក្នុងព្រៃមួយ ៗ បុរសជាប្តីនិយាយទៅកាន់ប្រពន្ធថា: "នៅទីនេះ មានគ្រោះថ្នាក់ច្រើនណាស់ ចូរប្អូនដោះគ្រឿងអលង្ការរបស់ប្អូនទាំងអស់ឲ្យមកបង បងទុកឲ្យ, ហើយបងឲ្យប្អូនត្រឡប់ទៅវិញ កាលណាយើងចូលទៅក្នុងស្រុក" ។

ប្រពន្ធដោះគ្រឿងអលង្ការរបស់ខ្លួនឲ្យទៅបុរសជាប្តី ៗ ដល់បានគ្រឿងអស់នោះកាលណា ក៏សម្លាប់ខ្ញុំម្នាក់ចោលទៅក្នុងអណ្តូង, រួចច្រានប្រពន្ធដែលខ្លួនបានហូតយកទ្រព្យអស់ហើយទំលាក់ទៅក្នុងអណ្តូងនោះ ហើយចាប់ដើរទៅមុខទៀតទៅ ។

ប៉ុន្តែមានអ្នកដំណើរម្នាក់ដើរតាមផ្លូវនោះ បានឮសូរមនុស្សម្នាក់យំៈគ ក៏ឈប់រកមើល តើសូរទំនួញនោះចេញពីខាងណា ក្នុងព្រៃនោះមក? ។

អ្នកដំណើរលុះបានដម្រង់ទៅទីដែលសូរសព្ទហាក់ចេញមកនោះ គេបានទៅដល់មាត់អណ្ដូងមួយ លុះចោលកន្ទុយភ្នែកទៅ ក៏ភ្ញាក់ស្មារតី ដោយឃើញស្រីម្នាក់យំ, លុះទាញស្រីនោះចេញអំពីអណ្ដូងមក គេសួរថា: "នាងកូនចៅអ្នកណា ហើយនាងធ្លាក់ចូលក្នុងអណ្ដូងនេះយ៉ាងណា?" ។ នាងឆ្លើយវិញថា: "ខ្ញុំជាកូនរបស់អ្នកជំនួញម្នាក់ឈ្មោះ ហោមគុប្ត ខ្ញុំជូនប្ដីខ្ញុំទៅស្រុករបស់គេវិញ ស្រាប់តែពួកចោរមកព័ទ្ធជុំវិញខ្លួនយើង សម្លាប់ទាសីខ្ញុំម្នាក់ ទំលាក់ខ្ញុំមកក្នុងអណ្ដូងនេះ រួចទៅបាត់ទៅ ដោយបានយកគ្រឿងមាសពេជ្រ និងប្ដីរបស់ខ្ញុំដែលវាចងជាប់ហើយ, តាំងពីនោះមក ខ្ញុំគ្មានបានដំណឹងអ្វីអំពីប្ដីខ្ញុំសោះ ឯគាត់ក៏គ្មានបានដំណឹងអ្វីពីខ្ញុំដែរ?" ។

លុះឮដូច្នោះ អ្នកដំណើរយកនាងទៅជាមួយខ្លួន ហើយនាំនាងទៅដល់មាត់ទ្វារឪពុករបស់នាង ។

ឪពុកម្ដាយរបស់នាង ដល់បានឃើញនាង សួរនាងអំពីហេតុដែលកើតឡើងនោះ ។ នាងឆ្លើយថា: "ចោរបានប្លន់យើងតាមផ្លូវ វាសម្លាប់អ្នកបំរើខ្ញុំម្នាក់ ចោលខ្មោចទៅក្នុងអណ្ដូងមួយ, ឯរូបខ្ញុំវាយកទៅទំលាក់ក្នុងអណ្ដូងងងឹតមួយទៀត រួចលុះកាលណាវាវាយដំប្ដីខ្ញុំហើយ វាអូសយកទៅព្រមទាំងគ្រឿងមាសពេជ្ររបស់ខ្ញុំផង វាទារលុយអំពីប្ដីខ្ញុំ គាត់ក៏ឆ្លើយទៅវាវិញថា: គាត់អស់គ្មានសល់ឡើយ ខ្ញុំមិនដឹងជាវាសម្លាប់គាត់ ឬ ចោលគាត់យ៉ាងណាទេ" ។

ឪពុករបស់នាងនិយាយថា: "កូនស្រីកុំព្រួយអ្វី ព្រោះរឿងនេះ ប្ដីឯងរស់ជីវិត ហើយបើទេវតាលោកជួយ ប្ដីឯងនឹងមករកឯងឆាប់ៗ មិនខាន ព្រោះបើចោរវាយកលុយ វាមិនយកជីវិតទេ". ។

នាយឈ្នួញបានឲ្យគ្រឿងមាសពេជ្រឯទៀតទៅនាង ដើម្បីជំនួសរបស់បាត់ផង ដើម្បីកុំឲ្យនាងព្រួយផង ដើម្បីលួងលោមនាងផង ។

ឯប្ដីរបស់នាង លុះលក់គ្រឿងមាសពេជ្រអស់ស្រេចកាលណា ដើរលេងល្បែងផ្សេងៗ ទាំងថ្ងៃទាំងយប់ពាល់តែអស់លុយទៅ ។

គាត់ត្រូវការបាយ ក៏រស់នៅក្នុងទុក្ខវេទនាមួយយ៉ាងធំ ។ លុះគាត់លំបាកដូច្នេះ ទើបគាត់នឹកឃើញថា: "អញនឹងត្រឡប់ទៅផ្ទះរបស់ឪពុកក្មេកអញវិញ រួចអញសុំទោសគាត់ដោយនិយាយថា ឪពុកក្មេកអញមានចៅមួយហើយ, អញមកនេះ ដើម្បីជូនពរសព្ទសាធុការ" ។ លុះគិតស្រេចយ៉ាងនេះ បុរសក៏ចេញដើរទៅ បន្តិចក្រោយមក បានទៅដល់ផ្ទះឪពុកក្មេករបស់ខ្លួនវិញ ។ គាត់ចង់ចូលទៅ ប៉ុន្តែប្រពន្ធរបស់គាត់ ដែលនៅបំពីមុខគាត់ក្នុងពេលនោះ បានឃើញគាត់ ហើយខ្លាចជាពន់ពេក គាត់ក៏ពុំហ៊ានដើរទៅមុខទៀត ប៉ុន្តែមិនត្រឡប់ទៅក្រោយវិញដែរ ។ នាងក៏ដើរទៅជិតហើយនិយាយរកគាត់ថា: "ម្ចាស់បង! កុំខ្លាចអ្វីឲ្យសោះ ប្អូនបាននិយាយប្រាប់ឪពុកប្អូនថា ចោរមកដល់ សម្លាប់អ្នកបំរើរបស់ប្អូនម្នាក់ យកមាសពេជ្ររបស់ប្អូន រួចដល់វាទំលាក់ចោលប្អូនទៅក្នុង.

អណ្តូងមួយហើយ ក៏យកប្តីរបស់ប្អូនទៅ ក៏កប់ដីប្តីរបស់ប្អូននេះទៀត; ហេតុដូច្នេះ សូមបងនិទានប្រាប់ឪពុករបស់ប្អូន តាមរឿងនេះចុះ រួចប្អូនជាខ្ញុំកម្តរបស់បងហើយ" លុះនិយាយដូច្នោះហើយ នាងក៏ចូលទៅក្នុងផ្ទះវិញ ។ ឯបុរសក៏ទៅជិតនាយឈ្មួញដែលក្រោកឈរឡើងទទួលបុរសនោះ ហើយសាកសួរបុរសអំពីដំណើរទំនងដែលមាននោះ ។ បុរសក៏និទានរឿងតាមដែលប្រពន្ធរបស់ខ្លួនបាននិយាយប្រាប់ រួចសេចក្តីសប្បាយក៏កើតមានឡើងពេញគ្រួសារ ។

ឯនាយឈ្មួញ ក៏ឲ្យបុរសងូតទឹក បរិភោគអាហារ ធ្វើឲ្យបុរសប្រែងស្មារតី រួចនិយាយថា: "ផ្ទះនេះរបស់កូនហើយ! នៅចុះ ហើយឲ្យបានសុខសប្បាយ" ។

កន្លងក្រោយពីនោះមក ក្នុងពេលរាត្រីមួយនោះ នាងប្រពន្ធ លុះពាក់គ្រឿងមាសពេជ្ររួច ក៏ដេកជិតបុរសហើយលក់ទៅ ។ ដល់ពេលម៉ោងពីរយប់ កន្លងផុតទៅ គឺដល់បុរសឃើញនាងលក់ស្កប់ស្កល់ ក៏យកកាំបិតស្នៀតមួយ ក៏ចាក់នាងចំដើមក រួចនាងក៏ស្លាប់ទៅ, លុះយកគ្រឿងមាសពេជ្រអស់ពីខ្លួននាងហើយ ក៏រត់ទៅស្រុកវាទៅ ។

លុះនិយាយដូច្នេះហើយ ល្ងោបេកបន្ថែមថា: "មហារាជ! ខ្ញុំជាសាក្សីធំនៃរឿងនេះ, ហេតុដូច្នេះហើយ បានជាខ្ញុំមិនចង់ត្រូវការនឹងឈ្មោលណាមួយឡើយ, ឱព្រះមហាក្សត្រិយ៍! សូមទ្រង់យល់ថា:

មនុស្សប្រុសជាចោរប្លន់មួយ, សូមទ្រង់មានព្រះរាជឧង្ការប្រាប់មកទូលបង្គំមើល? តើត្រូវប្រុសដូចជាគេចិញ្ចឹមពស់មួយនៅក្នុងផ្ទះឬទេ, ដែលស្រីទៅជាប់ខ្លួននឹងសត្វបែបនេះ? មហារាជ! សូមទ្រង់គិតពិចារណាមើលរឿងនេះ រួចសូមទ្រង់មានព្រះរាជឧង្ការប្រាប់ទូលបង្គំជាខ្ញុំវិញ តើទោសបែបណាដែលស្រីបានប្រព្រឹត្តអាក្រក់ទៅរកស្វាមី? សូមនិទានមកមើល ។

លុះទ្រង់ព្រះសណ្ដាប់យ៉ាងដូច្នេះ ស្ដេចទ្រង់បែរទៅរកសេកហើយមានបន្ទូលថា: "នែសេក! ចូរឯងប្រាប់អញមកមើល តើអំពើអាក្រក់ដែលគេប្រទះនៅក្នុងរូបស្រីនោះយ៉ាងណាខ្លះ? ។

សេកនិយាយថា: "មហារាជ! សូមទ្រង់ស្ដាប់ទូលព្រះបង្គំ" ។

(មានត)

# ពិធីបុណ្យដ៏ឧឡារិក

## នៅវត្តដើមអម្ពិល ខែត្រតាកែវ (ឃៀកណាម)

## ព្រះមហាឈិត កំលឹង

សិស្សសាលាបាលីជាន់ខ្ពស់ ថ្នាក់ទី ៤ (ក) វត្តឧណ្ណាលោម ក្រុងភ្នំពេញ រៀបរៀង

---

កាលពីថ្ងៃ ១៤-១៥ កើតខែមាឃ ឆ្នាំខាលទោស័ក ព. ស. ២៤៩៣ ក្រុមពុទ្ធបរិស័ទចំណុះវត្តដើមអម្ពិល ខែត្រតាកែវ (ឃៀកណាម) មានព្រះគ្រូសុខុមបញ្ញោ ចៅអធិការ, ព្រះគ្រូវិបស្សនាចារ្យសឹន - ឧត្តម៌ធម្មានុសាសនវិធី, ព្រះតេជព្រះគុណមហាគឹម - ឃួន អតីតសាស្ត្រាចារ្យជាអ្នកឧបត្ថម្ភនៃសាសនសិក្សា សម្រាប់សាលាបរិយត្តិបឋមវិជ្ជា វត្តដើមអម្ពិល ព្រះមហាលីវ-កែម សាស្ត្រាចារ្យ សម្រាប់សាលាបរិយត្តិបឋមវិជ្ជាវត្តដើមអម្ពិល (បច្ចុប្បន្ន) បានធ្វើពិធីបុណ្យដ៏ឧឡារិក ច្រើនផែក គឺ:

១ – បុណ្យសម្ពោធឆ្លងសាលាបរិយត្តិបឋមវិជ្ជា បណ្ដោយ ២៦ ម. ៥០, ទទឹង ១១ ម.៥០ ជញ្ជាំងឥដ្ឋ, សសរទ្វារបង្អួចទឹងគ្រឿងលើធ្វើពីឈើ ប្រក់ក្បឿង ។

២ – បុណ្យសម្ពោធឆ្លងអគ្គិកត្តសាលា (រោងភ្លើង) បណ្ដោយ ២០ ម. ទទឹង ៩ ម, ជញ្ជាំងឥដ្ឋ សសរទ្វារបង្អួចទឹងគ្រឿងលើធ្វើពីឈើ ប្រក់ក្បឿង ។

៣ — បុណ្យសម្ពោធឆ្លងសមាធិដ្ឋាន ១០ ខ្នងធ្វើពីឈើ ហើយក្នុងសមាធិដ្ឋានមួយខ្នងៗ មានបណ្តោយ ២ ម. ៥០, ទទឹង ២ ម. ដូចគ្នាទាំងអស់ ។

៤ — បុណ្យផ្កាស្រូវ ដើម្បីប្រមូលផ្គុំទូរហិរញ្ញវត្ថុយកទៅកសាងក្លោងទ្វារ និងកំពែងជាអវសានកិច្ចតទៅ ។

៥ — បុណ្យសម្ពោធសមណសក្តិ ស្រោចទឹកតាំងគ្រូសូត្រថ្មី ។

## កម្មវិធីបុណ្យ

ថ្ងៃទី ១ — ក្នុងថ្ងៃ ១៤ កើតខែមាឃ មុនម៉ោង ៩ យប់ សូរពិងខ្ទរខ្ទារព្រមគ្នាក្នុងព្រះវិហារ ដែលជាសូរស័ព្ទចេញពីមាត់ពុទ្ធសាសនិក-ជន ចំនួនជាប្រមាណ ៥៥០ នាក់ ៗ លុះដល់ម៉ោង ៩ យប់ពុទ្ធបរិស័ទបាននិមន្តព្រះសង្ឃចំរើនព្រះបរិត្ត លុះព្រះសង្ឃចំរើនព្រះបរិត្តចប់ហើយ កិត្តិមហា ឈិត - កំលីន ក្រោកឡើងប្រកាសព្រះសង្ឃ និងពុទ្ធបរិស័ទទាំងអស់គ្នាឲ្យស្ងាត់មាត់ ដើម្បីចាំស្តាប់សុន្ទរកថា របស់អ្នកបណ្ឌិតស៊ីន-សាន គ្រូបង្រៀនសាលាបឋមវិជ្ជាបាកំង-ខ្មែរ (សុន្ទរកថាថ្លែងដោយមាត់ទទេ) ។ លុះចប់សុន្ទរកថាហើយ ព្រះសង្ឃសូត្រ "ជយន្តោ" ជាកិត្តិយសដល់អ្នកកសាងអគ្គិកគ្គសាលា (ពេងភ្លើង) លុះព្រះសង្ឃសូត្រ "ជយន្តោ" ចប់ហើយអ្នកបណ្ឌិតហាង - គៀង ក៏សូត្រសុន្ទរកថាតបទៅអ្នកបណ្ឌិតស៊ីន - សានវិញ (មាននៅខាងចុង) ។

បំណែកទៅឧបដ្ឋានសាលា ក្នុងវេលាម៉ោង ៨ នឹង ៣៥ នាទី ពុទ្ធបរិស័ទបានប្រជុំគ្នាមសក្ការព្រះរតនត្រ័យ រួចនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត ។ បន្ទាប់ពីព្រះសង្ឃចំរើនព្រះបរិត្តមក អ្នកបណ្ឌិតទៀង-ចាន់ ក្រោកឡើងសូត្រសុន្ទរកថា ជាជំនួសភិក្ខុមហាលីវ-កែម (មាននៅខាងចុង) ។ រួចហើយព្រះសង្ឃសូត្រ "ជយន្តោ" ជាកិត្តិយសដល់អ្នកកសាងសាលាបរិយត្តិបឋមវិជ្ជាតទៅ ។ លុះចប់ភិក្ខុមហា ឈិត-កំលីន ក្រោកឡើងសូត្រសុន្ទរកថាជាតំណាងជំនួស ភិក្ខុមហាគីម-ឃួន (មាននៅខាងចុង) ។

ដល់ម៉ោង ១០ នឹង ១៥ នាទី ភិក្ខុមហាលីវ-កែមនឹងភិក្ខុមហាឈិត-កំលីន សំដែងធម្មទេសនា ជារបៀបបុច្ឆា-វិសជ្ជនា ។

ថ្ងៃទី ២ — វេលាម៉ោង ៩ ព្រឹកថ្ងៃ ១៥ កើតខែមាឃ ជួបជុំពុទ្ធបរិស័ទនឹងភិក្ខុសាមណេរ អ្នកបណ្ឌិតទៀង-ចាន់ ក្រោកឡើងថ្លែងសុន្ទរកថា ដោយមាត់ទទេ អំពីសេចក្តីឧបការនៃការតាំងភិក្ខុមហាឈិតកំលីន នឹងភិក្ខុសែម-ហេង ឲ្យធ្វើជាគ្រូសូត្រឡើងក្នុងអាវាសវត្តដើមអម្ពិលតទៅ ។

ម៉ោង ១០ អ្នកអាចារ្យឡឹម-ឃួន អាចារ្យសម្រាប់វត្តដើមអម្ពិល ក្រោកឡើងប្រកាសដល់ពុទ្ធបរិស័ទទាំងអស់គ្នាថា "អស់លោក-អ្នកទាំងឡាយ! ដែលជាអ្នកមុខអ្នកការ ក្នុងអាវាសវត្តដើមអម្ពិលនេះទាំង

អស់គ្នា, សូមអញ្ជើញមកអង្គុយក្នុងទីចំពោះព្រះភក្ត្រ ភិក្ខុមហាឈិត-កំលីន នឹងភិក្ខុ សែម-ហេង ដើម្បីនឹងនិមន្តព្រះសង្ឃសូត្រ "ជយន្តោ" ជាជយមង្គលដល់ភិក្ខុទាំងពីររូបនេះ ។

ម៉ោង ១០ និង ១៥ នាទីអ្នកអាចារ្យឡឹម ឃួន បានយកទឹកដែលពុទ្ធបរិស័ទអប់ដោយទានទឹងធូប យកទៅស្រោចលើព្រះហស្តរបស់ភិក្ខុមហាឈិត-កំលីន. សែម ហេង ។ រួចហើយ ព្រះសង្ឃសូត្រ "ជយន្តោ" ។ លុះចប់ "ជយន្តោ" ហើយ ភិក្ខុមហាឈិត-កំលីន ក៏ក្រោកឡើងថ្លែងសុន្ទរកថា ទៅកាន់ព្រះសង្ឃនឹងពុទ្ធបរិស័ទ ដោយមាត់ទទេវិញដែរ តបនឹងសុន្ទរកថារបស់អ្នកបណ្ឌិតទៀង ចាន់ ។

## ឱវាទរបស់ព្រះមហាគីម-ឃួន

ជាអាចារ្យ វត្តដើមអម្ពិល

## ភិក្ខុមហាឈិត-កំលីន ស្មូត្រជំនួស

ក្នុងឱកាសនេះជាវេលាល្អ ប្រកបដោយនក្ខត្តឫក្សមានសិរីសួស្តី ដល់ក្រុមពុទ្ធបរិស័ទទាំងឡាយ បានមកជួបជុំគ្នាក្នុងទីសន្និបាតនេះ ដើម្បីនឹងធ្វើពិធីបើកសាលាបរិយត្តិនេះ ។ ដូច្នេះសូមលោកអ្នកទាំងឡាយជ្រាបថា: សាលាបរិយត្តិបឋមវិជ្ជា ក្នុងខែត្រពោធិ៍សាត់នេះ មានខ្លះដែរហើយ តែសាលាបរិយត្តិធម៌នោះ មិនទាន់ជាស្តុកស្តម្ភ មាំមួនប៉ុន្មាននៅឡើយទេ ។ ហេតុនេះហើយបានជាព្រះតេជព្រះគុណជាសាស្ត្រាចារ្យ

របស់អាត្មាភាពទាំងពីររូប នឹងទ្រង់ព្រះករុណាអាត្មាភាព ព្រមដោយពួកពុទ្ធបរិស័ទចំណុះវត្តទាំងអស់គ្នា បានចំប្រឹងប្រែងផ្តួចផ្តើមបង្កើតសាលាបរិយត្តិធម៌នេះឡើង មិនមានគិតដល់សេចក្តីនឿយហត់សោះឡើយ ។ ទោះស្រុកទេសដែលកំពុងវិបត្តិប្រែប្រួលយ៉ាងនេះ ក៏ដោយក៏នៅតែមានសេចក្តីប្រឹងប្រែងរកគ្រូបាអាចារ្យ ឲ្យខាងតែបានមកបង្ហាត់បង្រៀនច្បាប់ព្រះពុទ្ធសាសនាតទៅ មិនឲ្យអាក់ខាន ព្រោះឃើញថា: ខេមរជាតិយើងទាំងអស់គ្នា សុទ្ធតែជាអ្នកគោរពរាប់អានព្រះពុទ្ធសាសនា តាំងពីបុរាណកាលមកហើយ. ដូច្នេះគួរយើងទាំងអស់គ្នា យកចិត្តទុកដាក់ទំសិក្សារៀនសូត្រដោយហ្មត់ចត់ កុំធ្វើព្រងើយកន្តើយនឹងការរៀនសូត្រក្នុងផ្លូវបរិយត្តិនោះឲ្យសោះ , ព្រោះបុរាណភាសិតលោកពោលទុកថា:

"អក្សរសាស្ត្រខ្មែរនេះ ត្រូវខ្មែរបេះឲ្យហ្មត់ចត់
រិះរៀនតាមបែបបទ ស័ព្ទសន្ទត់អ្នកប្រាជ្ញប្រាយ ។
ជាតិខ្មែរមិនសាបសូន្យ ព្រោះតែកូនខ្មែរទាំងឡាយ
ទំសិក្សាខ្វល់ខ្វាយ ដោយសប្បាយយ៉ាងក្លៀវក្លា ។
ជាតិខ្មែរនឹងថ្កើងថ្កាន ដោយសារបានក្បួនអក្ខរ
មានបែបបទថ្លៃថ្លា តាមត្រាអក្សរសាស្ត្រ ។
បើអក្សរសូន្យហើយ កូនខ្មែរអើយនឹងវិនាស
គេជៀលថាផ្តេសផ្តាស ទុកជាសាសន៍គ្មានតម្លៃ ។

អក្សរសាស្ត្រចំរើន    នាំបង្កើនឲ្យជាតិថ្លៃ

ថ្កុំថ្កើងជាងសព្វថ្ងៃ    ទាន់សម័យយ៉ាងសំខាន់ ។

អក្សរតាងប្រទេស    គេវិសេសឃើញជាក់ស្ទាន់

ត្រូវខ្មែរដើរឲ្យទាន់    ដោយស្រួសពន់កុំរង៉ែក ។

ខំផ្ចិតតម្រង់ចិត្ត    ប៉ងគំនិតគិតគ្រប់គ្នា

តាក់តែងក្បួនតម្រា    គ្រាន់ទុកជាបែបទៅមុខ ។

ក្បួនខ្មែរក្បួននានា    ជាតិថ្លៃថ្លាឲ្យរើសទុក

របររួមឲ្យគ្រប់មុខ    ទុកជាក្បួនអក្សរសាស្ត្រ ។

ជាតិខ្មែរនឹងបានថ្កើង    ចំរើនឡើងដោយជាក់ច្បាស់

ដោយសារអក្សរសាស្ត្រ    កើតដេរដាសពេញផែនដី" ។

ដូច្នេះត្រូវយើងគ្រប់គ្នា ខំក្រេបជញ្ជក់យករសជាតិព្រះពុទ្ធសាសនា មកកំណត់ទុកក្នុងចិត្តគ្រប់ ៗ គ្នាតទៅ ។

ព្រះតេជព្រះគុណ !

ព្រះករុណា ទាំងឡាយ !

អស់លោកសាធុសប្បុរសទាំងអស់គ្នា !

លំដាប់តទៅនេះ ខ្ញុំព្រះករុណា-អាត្មាភាព នឹងសូមដកស្រង់ពុទ្ធភាសិតខ្លះ មកអធិប្បាយប្រគេន នឹងជំរាបប្រសាសន៍ ដើម្បីឲ្យសមទៅតាមរាជដីកា របស់មហា (          ) ដែលលោកបានថ្លែង

អម្បាញមិញនោះថា: "សូមឲ្យខ្ញុំព្រះករុណា - អាត្មាភាព មេត្តាប្រោសប្រទានធម្មទានដល់ភិក្ខុ សាមណេរ ឧបាសក ឧបាសិកា" ។ ហេតុនេះ ខ្ញុំព្រះករុណា - អាត្មាភាពសូមឧកាសដ៏ខ្លីនេះបន្តិច អំពីសំណាក់ព្រះតេជព្រះគុណ! ព្រះករុណាទាំងឡាយ! អស់លោកសាធុសប្បុរសទាំងអស់គ្នា! អធិប្បាយអំពីកិច្ច ២ យ៉ាង ដែលព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងតម្រៀបជាបទមាតិកាដូចតទៅនេះ:

១) បហានកិច្ច កិច្ចគឺការលះបង់ ។

២) ភាវនាកិច្ច កិច្ចគឺការចំរើន ។

អធិប្បាយថា: បហានកិច្ច កិច្ចគឺការលះបង់នោះ គឺលះបង់នូវបាបគឺអំពើដែលកើតឡើងអំពីកាយវាចាចិត្ត; បណ្ដាបាបទាំងនេះ ឥតមានចំណែកណាមួយ ដែលជារបស់គួរធ្វើ គួរប្រព្រឹត្តសោះឡើយ ។

កាលបើបុគ្គលណាមួយដ្រុលកាយ វាចា ចិត្ត ធ្វើអំពើបាបជាករណីយកិច្ចនោះហើយ ត្រូវដឹងខ្លួនថាមុខជានឹងមានទោស គឺសេចក្ដីក្ដៅក្រហាយក្នុងលោកទាំងពីរ គឺ: លោកនេះក្ដៅក្រហាយដោយគិតថា: អាត្មាអញបានធ្វើបាបយ៉ាងនេះយ៉ាងនោះ លុះច្យុតចាកលោកនេះទៅហើយនឹងរឹងរឹតតែក្ដៅក្រហាយជាងនេះទៅទៀត ។ ព្រោះហេតុនោះបានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា: បាបនេះជាអំពើគួរលះបង់ចេញនេះហៅថា បហានកិច្ច ។

ការនាកិច្ច កិច្ចគឺការចំរើននោះ បានដល់ការបំពេញកុសលឲ្យបរិបូណ៌ ។ កុសលនេះបើសំដែងដោយបុសគល់បានខាង អលោភោ គឺការមិនជំពាក់ចិត្តក្នុងទ្រព្យសម្បត្តិ មិនចង់បាននូវទ្រព្យរបស់បុគ្គលដទៃ តាំងមិនលួចលាក់ឆក់ដណ្តើមបំបាត់ប្រវ័ញ្ចន៍ សន្ធឹតសន្ធិទរីបជាន់យកធនធានរបស់បុគ្គលដទៃ, អទោសោ គឺការមិនប្រទូស្តខេ្ទងឹង មិនរករឿងរកហេតុអ្នកដទៃឲ្យដល់នូវសេចក្តីវិនាស, អមោហោ មិនវង្វេងកាន់តាំងក្លែបស្មារតី ដោយអ្នកដទៃគេគំរាមកំហែង បំភាន់គំនិតជាដើមឡើយ ។

មួយទៀត កុសលនេះបើសំដែងដោយទីកើតមាន ១០ ប្រការ មានការឲ្យនូវវត្ថុដ៏គួរដល់បុគ្គលដែលគួរឲ្យដោយសេចក្តីសង្រ្គោះ ឬបូជាគុណ មានឲ្យដល់មនុស្សកំសត់ ឬបូជាដល់លោកអ្នកមានសីលធម៌ នឹងមាតាបិតាជាដើម, មានការតាំងចិត្តស្តាប់ធម៌ ស្តាប់ពាក្យទូន្មានពាក្យប្រៀនប្រដៅ ដោយប្រុងឲ្យចេះចាំស្ទាត់ ធ្វើកើតនិយាយបានជាទីបំផុត ។

បុគ្គលណា បានធ្វើកុសលដូចពោលមកនេះ បុគ្គលនោះឲ្យសង្ឃឹមទុកចិត្តចុះ ថាមុខជាជួបប្រទះនូវសេចក្តីសុខ - សេចក្តីចំរើនក្នុងលោកនេះ នឹងលោកខាងមុខមិនខាន នេះហៅថា ការនាកិច្ច ។-

កិច្ចទាំង ២ យ៉ាងនេះ ជាដំណើរខាងផ្លូវធម៌, បើជាខាងផ្លូវលោកវិញ បហានកិច្ច (កិច្ចគឺការលះបង់) ត្រូវសំដៅយកការលះបង់នូវកិរិយាមារយាទអាក្រក់ ក្រអឺតក្រអោង អោងកាចខ្ជិលច្រអូស ដើរលេងស៊ីផឹក ចាយវាយទ្រព្យសម្បត្តិឥតប្រយោជន៍ ឥតសណ្តាប់ធ្នាប់ មានធ្វើចោរកម្ម លួចឆក់ដណ្តើមរបជាន់សង្កត់សង្កិនយកធនធានរបស់អ្នកដទៃជាដើម ។ អំពើទាំងអស់នេះ សុទ្ធតែជាអំពើនាំឲ្យថោកទាបឬទន់ខ្សោយ អាប់រស្មីដល់ខ្លួនឯង និងប្រទេសជាតិមាតុភូមិ ។ បុគ្គលអ្នកស្រឡាញ់សេចក្តីល្អ គួរតែនាំគ្នាលះបង់ចោល នូវអំពើអាក្រក់នេះចេញ ។

ភាវនាកិច្ច (កិច្ចគឺការចំរើន) សំដៅដល់ការព្យាយាមបំពេញកិច្ចរបស់ខ្លួនដែលត្រូវធ្វើឲ្យបានគ្រប់គ្រាន់ ព្រោះមនុស្សទាំងមួយៗ សុទ្ធតែមានសេចក្តីសុខ-ទុក្ខ ។ សេចក្តីសុខ-ទុក្ខកើតមកអំពីសេចក្តីព្យាយាមបំពេញចំរើនផលជាមុខការត្រូវធ្វើ ។

សូមទាញរឿងបមាខ្លះមកសំដែងក្នុងទីនេះ ឲ្យឃើញអានិសង្សនៃសេចក្តីព្យាយាម ។ យើងគួរយកគម្រប់តាមសត្វកណ្តៀរ, កណ្តៀរជាសត្វមានខ្លួនតូចណាស់, តែកណ្តៀរមានសាមគ្គីភាពព្រមព្រៀងគ្នាព្យាយាមជញ្ជូនដីបន្តិចម្តងៗ រាល់ថ្ងៃ កពូនកើតឡើងទៅជាដំបូកមួយយ៉ាងធំបាន ទៅជាផ្ទះសំបែងសម្រាប់ការពារញាតិមិត្រកូនចៅរបស់វាបានសេចក្តីសុខ-ចំរើន ឥតមានសត្រូវហ៊ានចូលលុកលុយ ទាំងសម្បូណ៌ដោយគ្រឿងចិញ្ចឹមជីវិតរបស់វាឥតមានខ្វះខាត ។

ម្យ៉ាងទៀត យើងគួរយកតម្រាប់ពួកជាតិផ្សេងៗ ធម្មតាពួកជាតិផ្សេងៗ ដំបូងឡើងមានឫសខ្ចីទន់ខ្សោយកម្លាំងណាស់ ទោះបីពួកជាតិនោះដុះចាក់ឫសចុះទៅលើធម្មជាតិណាមួយយ៉ាងរឹងប្រហែលគ្មានទីពឹង ក៏ពួកជាតិនោះ ខំរុលត្បុលប្រឹងចាក់ចុចសឹកសៀតបន្តិចម្តងៗ រាល់ថ្ងៃរហូតធ្វើឲ្យរបស់ដែលរឹងនោះ របើករបេះប្រេះបែកទៅដោយកម្លាំងព្យាយាមរបស់វាបាន, ហើយចាក់ឫសទៅដល់ផែនដីស្រូបយកកម្លាំងធាតុមកចិញ្ចឹមដើមរបស់វា ឲ្យរឹងរឹតតែមានកម្លាំងខ្លាំងឡើង ។ បុគ្គលណាពេញចិត្តក្នុងការបំពេញកិច្ចរបស់ខ្លួន ហើយបើទុកជាស្លាប់ក្នុងពេលកំពុងព្យាយាមបំពេញកិច្ចក៏បានឈ្មោះថាប្រសើរបំផុត ។ ខ្លួនបាត់ទៅហើយមែន! តែកេរ្តិ៍ឈ្មោះនៅល្អ, ខ្លួនស្លាប់ទៅចុះ! កុំឲ្យតែស្លាប់សេចក្តីព្យាយាម ។ សមដូចជាពុទ្ធភាសិតថា: "រូបនៃសត្វទាំងឡាយ រមែងស្លាប់ទៅ តែនាមនឹងគោត្រមិនស្លាប់ឡើយ" មួយទៀតថា "គេកន្លងនូវសេចក្តីទុក្ខបានដោយសេចក្តីព្យាយាម" ។

ក្នុងទីបំផុតនៃសុន្ទរកថានេះ សូមសុខសួស្តីសិរីវឌ្ឍនភាព មានដល់ព្រះតេជព្រះគុណ, ព្រះករុណាទាំងឡាយ, អស់លោកសាធុសប្បុរសទាំងអស់គ្នា ។

សូមព្រះតេជព្រះគុណ, ព្រះករុណាទាំងឡាយ, អស់លោកសាធុសប្បុរសទាំងអស់គ្នា ទទួលសន្តុដ្ឋីមេត្រីចិត្ត ដោយអភិវាទថាសាធុៗ គ្រប់ៗរូបតទៅ ។

(មានត)

## ឧត្តមគតិនៃពុទ្ធបរិសទ្យវត្តលង្កា ក្រុងភ្នំពេញ
## ដែលអ្នកផងគួរយកតម្រាប់តាម

---

សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ចៅអធិការវត្តលង្កា ក្រុងភ្នំពេញ បានពន្យល់ពុទ្ធបរិសទ្យ វត្តលង្កា អំពីប្រយោជន៍នៃការចូលជាសមាជិកភាព ក្នុងសមាគមមិត្តសាលាបាលី ព្រះសង្ឃនឹងឧបាសក - ឧបាសិកាដែលបានស្តាប់ កើតមានបសាទសទ្ធាចុះជាសមាជិកសមាជិកាបាន ២០៧ រូប ។ បន្ទាប់ពីនោះមក កាលនៅថ្ងៃ ២៧ ខែធ្នូ ឆ្នាំ ១៩៥១ មានធ្វើពិធីចែកបណ្ណសមាជិក ក្នុងទីវត្តនោះដល់ពុទ្ធបរិសទ្យដែលស្ម័គ្រចូលហើយ, ក្នុងពិធីនេះ មានព្រះសង្ឃ, ឧបាសក - ឧបាសិកាដែលមិនទាន់ចុះជាសមាជិកក៏បានចុះជាលំដាប់មកទៀត ចំនួន ៥០០ រូប ត្រូវជាប្រាក់ ៥០០០ រៀល ។

ឧត្តមគតិនៃពុទ្ធបរិសទ្យ វត្តលង្កានេះ ជាអនុស្សាវរីយ៍ចារឹកទុកក្នុងប្រវត្តិសាស្ត្រ នៃសមាគមមិត្តសាលាបាលីៗ សូមឲ្យកុសលចេតនានេះឆ្លងដល់ពុទ្ធបរិសទ្យគ្រប់វត្តក្នុងព្រះរាជធានីនឹងខែត្រក្រៅ គឺសូមឲ្យជួយឧបត្ថម្ភសមាគមនេះ ឲ្យបានចំរើនតទៅអនាគត ។

សមាគមមិត្តសាលាបាលី សូមគោរពទទួលអំណរដ៏ក្រៃលែងចំពោះពុទ្ធបរិសទ្យវត្តលង្កា មានសម្តេចព្រះធម្មលិខិត ល្វី-ឯម ជា

ប្រធាន ដោយតេជានុភាពនៃព្រះត្រៃរ័ត្ន នឹងបុញ្ញនិធិនេះ សូមសម្តេច, ព្រះថេរានុត្ថេរៈ, លោក-អ្នកទាំងឡាយ ឲ្យបានសមប្រកបតាមសេចក្តីប្រាថ្នា! សូមឲ្យមានសួស្តីជយមង្គលជានិរន្តរ៍! ក្នុងអវសានជាតិ សូមឲ្យបានសម្រេចព្រះនិព្វាន គ្រប់រូប នាម កុំបីឃ្លៀងឃ្លាតឡើយ!

## សមាគមមិត្តសាលាបាលី